## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ២៥១ "ខ"
ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១
សំណុំរឿងព្រហ្មទណ្ឌលេខ:៦៦៤
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០
សំណុំរឿងស៊ើបសួរលេខ:៣៤៧
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ:២០១
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តក្រចេះ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងខេត្តក្រចេះ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម:

### សមាសភាពជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តក្រចេះ។

-លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តក្រចេះ។

-លោកស្រី [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តក្រចេះ។

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តក្រចេះ។

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ត្បូងឃ្មុំ, ថ្ងៃទី........ ខែ........ ឆ្នាំ២០២១
ក្រឡាបញ្ជី

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ:៦៦៤ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] **ធី** ហៅ**ចិត្រ** ភេទប្រុស អាយុ ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីកន្លែងកំណើតនៅ [redacted] ខេត្តកណ្តាល។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិព្រែកអញ្ចាញ ឃុំព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។ ឪពុកឈ្មោះ [redacted] បូ"ស" ម្តាយឈ្មោះ [redacted] គុំ"រ"។ ប្រពន្ធឈ្មោះ [redacted] ចាន់សាវឿន មានកូន ០២នាក់។ ទោសពី [redacted] គ្មាន។ ឃុំខ្លួននៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:១៥៣/២០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគីរី។

២-ឈ្មោះ [redacted] **សុធារ៉ាន់** ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ អនុប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនគោក និងជាឧត្តមសេនីយ៍ទោ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកំពង់ចាម។ ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះលេខ:C២៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] ម៉េង"ស" ម្តាយឈ្មោះ [redacted] ពៅ"ស"។ ប្រពន្ធឈ្មោះ [redacted] បុទំ មានកូន ០៣នាក់។ ទោសពីមុនគ្មាន។ ឃុំខ្លួននៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:១៤៧/២០ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តមណ្ឌលគីរី។

៣-ឈ្មោះ [redacted] **ឈិន** ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន LPRO SOLAR ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តតាកែវ។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិដូងខ្ពស់ ឃុំបាកាន ស្រុកព្រែកប្បាស ខេត្តតាកែវ។ ឪពុកឈ្មោះ [redacted] អៃ "រ" ម្តាយឈ្មោះ [redacted] គាង"រ"។ ប្រពន្ធឈ្មោះ [redacted] ផល្លី(លែងលះ) មានកូន០២នាក់។ ទោសពីមុនគ្មាន។ ឃុំខ្លួននៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១៤០/២០ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តមណ្ឌលគីរី។

៤-ឈ្មោះ [redacted] **បញ្ញាតា** ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន(លក់អចលនទ្រព្យ)ទីកន្លែងកំណើតនៅ [redacted] ក្រុងភ្នំពេញ។ ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះលេខ៣៣ ផ្លូវលេខ១៣៦ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានី



Scanned with CamScanner

ភ្នំពេញ។ ឪពុកឈ្មោះ[redacted] ងួនលី"រ" ម្តាយឈ្មោះ[redacted] យ៉េកហៀង"រ"។ ប្រពន្ធឈ្មោះ[redacted] ជោគវាសនា មានកូន០៤នាក់។ ទោសពីមុនគ្មាន។ ឃុំខ្លួននៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៣៨៣ ឃ.ខ/២០២០ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

៥-ឈ្មោះ[redacted] **ធូន** ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរ ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពត។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិមិល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ឪពុកឈ្មោះសាង ហេង"រ" ម្តាយឈ្មោះ[redacted] ឃីម"រ"។ ប្រពន្ធឈ្មោះ[redacted] សុខឡា មានកូន ០១នាក់។ ទោសពីមុនគ្មាន។ ឃុំខ្លួននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:៤១៩ ឃ.ខ/២០២០ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

៦-ឈ្មោះ[redacted] **ម៉េងធី** ភេទប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរ អ្នកសារព័ត៌មាន ទីកន្លែងកំណើតនៅភូមិ[redacted] រាជធានីភ្នំពេញ។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិចំការតែ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ឪពុកឈ្មោះ[redacted] ចាន់"ស" ម្តាយឈ្មោះ[redacted] ម៉ុំ"រ"។ ពោះម៉ាយ មានកូន ០២នាក់។ ទោសពីមុនគ្មាន។ ឃុំខ្លួននៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:១៤៣/២០ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគិរី។

៧-ឈ្មោះ[redacted] **ដុខ** ភេទប្រុស អាយុ ៥១ឆ្នាំ ជាតិខ្មែរ មុខរបរ នគរបាល ទីកន្លែងកំណើត[redacted] ខេត្តកំពង់ចាម។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិអូររអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ ឪពុកឈ្មោះ[redacted] សុខ"រ" ម្តាយឈ្មោះ[redacted] លី"រ"។ ប្រពន្ធឈ្មោះ[redacted] ឡា មានកូន ០៣នាក់។ ទោសពីមុនគ្មាន។ ឃុំខ្លួននៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:១៤១/២០ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគិរី។

៨-ឈ្មោះ[redacted] **សុភក្តិ** ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីរដ្ឋបាលព្រៃឈើ ឋាន:នាយរងខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី ទីកន្លែងកំណើតនៅភូ[redacted] ខេត្តព្រៃវែង។ ទីលំនៅសព្វថ្ងៃនៅភូមិចំការតែ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ឪពុកឈ្មោ[redacted] ស៊ាន"រ" ម្តាយឈ្មោះ[redacted] ស៊ីប៊ាប"ស"។ ប្រពន្ធឈ្មោះ[redacted] យ៉ានី មានកូន ០២នាក់។ ទោសពីមុនគ្មាន។ ក្រៅឃុំ តាមដីកាសម្រេចមិនឃុំខ្លួនលេខ:២៩៥ ព.ស/២១ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

៩-ឈ្មោះ[redacted] **សុខា** ភេទប្រុស អាយុ ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីរដ្ឋបាលព្រៃឈើ ឋាន:នាយផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យ ទីកន្លែងកំណើតនៅ[redacted] រាជធានីភ្នំពេញ។ ទីលំនៅសព្វថ្ងៃនៅភូមិចំការតែ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ឪពុកឈ្មោះ[redacted] ចែម"រ" ម្តាយឈ្មោះ[redacted] វឿន"ស"។ ប្រពន្ធឈ្មោះ[redacted] ថាវី មានកូន ០៤នាក់។ ទោសពីមុនគ្មាន។ ក្រៅឃុំ តាមដីកាសម្រេចមិនឃុំខ្លួនលេខ:២៩៦ ព.ស/២១ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

១០-ឈ្មោះ[redacted] **វណ្ណារ័ត្ន** ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីសុរិយោដីខេត្តមណ្ឌលគិរី ទីកន្លែងកំណើតនៅភូ[redacted] ខេត្តមណ្ឌលគិរី។ ទីលំនៅសព្វថ្ងៃនៅភូមិមានលាភ សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ឪពុកឈ្មោះ[redacted] វណ្ណារ៉ា"រ" ម្តាយឈ្មោះ[redacted] ចាន់ធីតា"រ"។ ប្រពន្ធឈ្មោះ[redacted] ចាន់រី មានកូន ០២នាក់។ ក្រៅឃុំ តាមដីកាសម្រេចមិនឃុំខ្លួនលេខ:៦៣៦៣ ព.ស/២០ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។



Scanned with CamScanner

១១-ឈ្មោះ[redacted] **សុខេខ** ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរប្រធានការិយាល័យស្រុកអូររាំង(ក្រសួងដែនដី) ទីកន្លែងកំណើត[redacted] ខេត្តមណ្ឌលគីរី។ ទីលំនៅសព្វថ្ងៃនៅភូមិពូរាំង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគីរី។ ឪពុកឈ្មោះលឹម លាង"រ" ម្តាយឈ្មោះ[redacted] សារីម"ស"។ ប្រពន្ធឈ្មោះ[redacted] យេន មានកូន ០៦នាក់។ ទោសពីមុនគ្មាន។ ក្រៅឃុំ តាមដីកាបង្គាប់ឲ្យដោះលែងលេខ:៦៣/២០ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគីរី។

១២-ឈ្មោះ[redacted] **ម៉ាច់** ហៅ[redacted]**ប៊ូស្រា** ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តមណ្ឌលគីរី។ ទីលំនៅសព្វថ្ងៃនៅភូមិពូរាំង ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី។ ឪពុកឈ្មោះសារឿន"រ" ម្តាយឈ្មោះ[redacted] មុន"រ" ។ ប្រពន្ធឈ្មោះ[redacted] ឆរី មានកូន ០៥នាក់។ ក្រៅឃុំ មានដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ:៤១ /២០ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគីរី។

១៣-ឈ្មោះ[redacted] **សំណាង** ហៅ[redacted]**ធាហ៊ាន** ភេទប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីកន្លែងកំណើត[redacted] ខេត្តព្រៃវែង។ ទីលំនៅសព្វថ្ងៃនៅភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី។ ឪពុកឈ្មោះ[redacted] ឈួរ"រ" ម្តាយឈ្មោះ[redacted]លី"រ"។ ប្រពន្ធឈ្មោះ[redacted] ចន្ទ្រា មានកូន ០១នាក់។ ក្រៅឃុំ មានដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ៤០/២០ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគីរី។

បានចំលងត្រឹមត្រូវតាមច្បាប់ដើម។
ត្បូងឃ្មុំ ថ្ងៃទី ០៥ ខែ ០៩ ឆ្នាំ២០២១.
ក្រឡាបញ្ជី

១៤-ឈ្មោះ[redacted]**ចន** ហៅ**សុវណ្ណឌី** ភេទប្រុស អាយុ ៦០ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីនគរបាលចូលនិវត្តន៍ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ធំ។ ទីលំនៅសព្វថ្ងៃនៅភូមិដោះក្រមុំ សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី។ ឪពុកឈ្មោះ[redacted] ឌុន"រ" ម្តាយឈ្មោះ[redacted]រ័ត"ស"។ ប្រពន្ធឈ្មោះ[redacted] កាន់ធឿន មានកូន ០៤នាក់។ ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ:៣៧/២០ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគីរី។

[redacted]

១៥-ឈ្មោះ[redacted] **សាន** ភេទប្រុស ជាតិខ្មែរ [redacted] ខេត្តមណ្ឌលគីរី។ ក្រៅឃុំ ដីកាបង្គាប់ឲ្យចូលខ្លួនលេខ៥៩៦៨ ព.ស/២០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ពីបទ: **កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

-មេធាវីការពារជនជាប់ចោទឈ្មោះ[redacted]។

-មេធាវីការពារជនជាប់ចោទឈ្មោះ[redacted]

-មេធាវីការពារជនជាប់ចោទឈ្មោ[redacted]

, លោកមេធាវី[redacted]

-មេធាវីការពារឈ្មោ[redacted]

មេធាវី[redacted]



Scanned with CamScanner

-មេធាវីការពារជនជាប់ចោទឈ្មោះ[redacted]។

-មេធាវីការពារជនជាប់ចោទឈ្មោ[redacted]

-មេធាវីការពារជនជាប់ចោទឈ្មោ[redacted]

-មេធាវីការពារជនជាប់ចោទឈ្មោ[redacted]

-មេធាវីការពារជនជាប់ចោទឈ្មោ[redacted]**សុខា**, ជនជាប់ចោទឈ្មោ[redacted]**សុគន្ធី**, ជនជាប់ចោទឈ្មោះ[redacted] **ម៉ាប់** ហៅ[redacted]**ម៉ុស្រា**, ជនជាប់ចោទឈ្មោះ[redacted] **សំណាង** ហៅ[redacted]**ទាហ៊ាន**, ជនជាប់ចោទឈ្មោះ[redacted] **សាន** គឺលោកមេធាវី [redacted]

-**បានឃើញ** ដីកាសម្រេចផ្ទេរសមត្ថកិច្ចលេខ:១៦៣៥/២០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តមណ្ឌលគិរី។

-**បានឃើញ** របាយការណ៍លេខ:០២៦/២០ រ.ប.ក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ:២៨២/២០ អ.យ.ក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ:០៨៣ អ.យ.ក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តក្រចេះ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ:៦៥៦ ព.ស/២១ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

## **<u>អង្គហេតុនៃរឿងមានដូចតទៅ:</u>**

-ជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ ភេទប្រុស អាយុ ៥៥ឆ្នាំ មានដីទំហំ ២៩៨ហិចតា នៅចំណុចភ្នំរបាំង ស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដោយដីនោះមានការចុះហត្ថលេខាពីអាជ្ញាធរភូមិ ឃុំ និងស្រុក។ ជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ មានបំណងធ្វើការអភិវឌ្ឍន៍លើដីនោះដោយបាននិយាយប្រាប់ទៅជនជាប់ចោទឈ្មោះ[redacted] សុផារ៉ាន់ ភេទប្រុស អាយុ ៤៣ឆ្នាំ។ បន្ទាប់មកជនជាប់ចោទឈ្មោ[redacted] សុផារ៉ាន់ បានប្រាប់រឿងរ៉ាវនេះដល់ជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា ភេទប្រុស អាយុ ៣៩ឆ្នាំ ហើយជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា បាននែនាំឲ្យជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ បានជួប និងស្គាល់ជនជាប់ចោទឈ្មោះ[redacted] ឈិន ភេទប្រុស អាយុ ៣៦ឆ្នាំ និងបានចុះកិច្ចសន្យាព្រមព្រៀងវិនិយោគអចលនទ្រព្យ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ រវាងជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ និងជនជាប់ចោទឈ្មោះ[redacted] ឈិន ដោយមានឈ្មោះ[redacted] សុផារ៉ាន់ ជាសាក្សីឲ្យឈ្មោះ[redacted] ធី, ឈ្មោ[redacted] បញ្ញាភា ជាសាក្សីឲ្យឈ្មោះ[redacted] ឈិន លើដីទំហំ ២០០ហិចតា នៅចំណុចភ្នំរបាំង ស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដោយជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ មានភាគហ៊ុនចំនួន ៦០ភាគរយ និងជនជាប់ចោទឈ្មោះ[redacted] ឈិន មានភាគហ៊ុនចំនួន ៤០ភាគរយ។ បន្ទាប់មកបានបង្កើតក្រុមហ៊ុនដាក់ដាំអ៊ិនវេស៍មិន(មិនទាន់ចុះបញ្ជី) ដើម្បីបង្កើតរីស៊ត។ ក្រោយមកជនជាប់ចោទឈ្មោ[redacted] វណ្ណារ័ត្ន ភេទប្រុស អាយុ ៣៣ឆ្នាំ បានចុះទៅវាស់វែងចុចGPS កំណត់ទីតាំង និងកំណត់ព្រំដីនោះហើយជនជាប់ចោទឈ្មោះ[redacted] សុខេង ភេទប្រុស អាយុ ៤៤ឆ្នាំ ជាអ្នកចុះហត្ថលេខាលើប្លង់ដីម៉ាសGPS ដែលការវាស់វែងនោះតាមការស្នើរបស់ជនជាប់ចោទឈ្មោះ[redacted]



Scanned with CamScanner

ធី ហៅចិត្រ។ លុះដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ កម្លាំងក្រុមការងារចម្រុះថ្នាក់ក្រោមជាតិបានការចុះបង្ក្រាបបទល្មើសជាក់ស្តែងនៅទីតាំងដែលជនជាប់ចោទបានយកគ្រឿងចក្រធ្វើសកម្មភាពកាប់គាស់ និងរុករានឈូសឆាយដីព្រៃដោយគ្មានការអនុញ្ញាតនៅលើដីចំណុចភ្នំរបហាំង ស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដែលគូកនរបស់ជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ រួមមាន ជនជាប់ចោទឈ្មោះ[redacted] ម៉េងធី ភេទប្រុស អាយុ ៤៧ឆ្នាំ, ជនជាប់ចោទឈ្មោះ[redacted] ជុង ភេទប្រុស អាយុ ៥១ឆ្នាំ, ជនជាប់ចោទឈ្មោះ[redacted]វន ហៅសុវណ្ណឌី ភេទប្រុស អាយុ ៦០ឆ្នាំ, ជនជាប់ចោទឈ្មោះ[redacted] សំណាង ហៅណាង ទាហ៊ាន ភេទប្រុស អាយុ ៤៧ឆ្នាំ, ជនជាប់ចោទឈ្មោះ[redacted] សុភក្តិ ភេទប្រុស អាយុ ៤៥ឆ្នាំ, ជនជាប់ចោទឈ្មោះ[redacted] សុខា ភេទប្រុស អាយុ ៤៨ឆ្នាំ, និងជនជាប់ចោទឈ្មោះ[redacted]ម៉ាប់ ហៅម៉ាប់ប៊្លីស្រា ភេទប្រុស អាយុ ៤២ឆ្នាំ ហើយត្រូវបានកម្លាំងក្រុមការងារចម្រុះថ្នាក់ក្រោមជាតិធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ[redacted] ឈិន និងបន្តការស្រាវជាវ ហើយជនជាប់ចោទទៀតខ្លះក៏បានរត់គេចខ្លួនតែម្តង។

## **នាពេលសវនាការ**

១-ជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ បានឆ្លើយបញ្ជាក់ថា: ខ្លួនបានស្គាល់ឈ្មោះ[redacted] ឈិន, ឈ្មោះ[redacted] សុធារ៉ាន់, ឈ្មោះ[redacted] ជុង, ឈ្មោះ[redacted]ម៉េងធី,ឈ្មោះ[redacted]សុភក្រ័ក្តិ, ឈ្មោះ[redacted] ស្ទូ និងឈ្មោះ[redacted] ម៉ាប់។ ក្រោយមកខ្លួនបានឱ្យឈ្មោះ[redacted] សុធារ៉ាន់ ណែនាំឈ្មោះ[redacted] ឈិន ឲ្យខ្លួនស្គាល់ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍ និងឲ្យប្រាក់កម្រៃជើងសារទៅឈ្មោះ[redacted] សុធារ៉ាន់។ ខ្លួនសូមអះអាងថាដីដែលខ្លួនចង់អភិវឌ្ឍន៍នេះ គឺជាដីដែលខ្លួនទិញពីប្រជា[illegible] ចំនួន ២៩៨ ហិចតា នៅចំណុចភ្នំក្បាលខ្មោច ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្ត[illegible] និងឆ្នាំ[illegible] ដោយមានចុះហត្ថលេខាមេភូមិ គឺលោក[redacted]ឈិន និងមេឃុំ គឺលោក[redacted] វ៉ាន់ឌី និងអភិបាលស្រុក[illegible]ស៊ិន ដោយដីនេះមានការវាស់វែងកំណត់ព្រំដីដោយមានប្លង់ឌីម៉ាស់វាស់វែងដោយGPS ត្រឹមត្រូវ ចេញដោយមន្ត្រីវាស់វែង និងមានការចុះហត្ថលេខាដោយប្រធានភូមិចាលស្រុកអូររាំង តែមិនមានការទទួលស្គាល់ពីសុរិយោដីនោះទេ ហើយដីនោះមិនមានការពាក់ព័ន្ធជាមួយជម្រកព្រៃឈើតំបន់ធម្មជាតិនោះទេ ដោយដីទាំងនោះមានដាំដំណាំធូរ៉េន ចំនួន២០ហិចតា និងដាំដំណាំផ្សេង[redacted] ផ្ទៃដីចំនួន ៣ហិចតា។ ក្រោយមក នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ ខ្លួនបានចុះកិច្ចព្រមព្រៀងគ្នាជាមួយឈ្មោះ[redacted] ឈិន តាមការណែនាំរបស់ឈ្មោះ[redacted] សុធារ៉ាន់ លើការវិនិយោគដីទំហំ ២៨៩ ហិចតា ខាងលើ។ ចំពោះកិច្ចសន្យាវិនិយោគដីនេះ គឺមានភាគីម្ចាស់ដីតែខ្លួនម្នាក់គត់ ចំណែកឯភាគីខាងវិនិយោគរួមមានឈ្មោះ[redacted] ឈិន, ឈ្មោះ[redacted] ធួន, ឈ្មោះ[redacted] បញ្ញាភា និងឈ្មោះ[redacted] សុធារ៉ាន់ ដោយក្នុងកិច្ចព្រមព្រៀងនោះខ្លួនមានភាគហ៊ុន ចំនួន៦០% ជាភាគីម្ចាស់ដី និងភាគីវិនិយោគមានភាគហ៊ុនចំនួន ៤០%។ ចំណែកឯរឿងវិនិយោគនោះ ខ្លួនមិនដឹងថាពួកគេបានលុយមកពីណានោះទេ។ បន្ទាប់ពីចុះកិច្ចសន្យារួចមក ខ្លួនមានកាតព្វកិច្ចជាអ្នកទទួលខុសត្រូវលើដីរាល់ការពាក់ព័ន្ធជាមួយគម្របព្រៃឈើ តំបន់ធម្មជាតិ ឬពាក់ព័ន្ធជាមួយកម្មសិទ្ធិរបស់អ្នកណាម្នាក់ និងមានកាតព្វកិច្ចយកគ្រឿងចក្រយកមកធ្វើការឈូសឆាយផ្លូវ។ ចំពោះការឈូសឆាយផ្លូវនេះ ខ្លួនបានទៅសុំអាជ្ញាធរភូមិឃុំដោយផ្ទាល់មាត់ រីឯគ្រឿងចក្រត្រាក់ទ័រ គឺឈ្មោះ[redacted] ម៉ាប់ ជាអ្នកជួល និងមើលការខុសត្រូវ។ រីឯក្រុមវិនិយោគបានសាងសង់ផ្ទះមួយ និងតូបកាហ្វេមួយ ដែលការសាងសង់នោះគឺសាងសង់លើកំពូលភ្នំ និងមិនបានឈូសដើមឈើអ្វីនោះទេ។ លុះនៅថ្ងៃខែមិនចាំ ឈ្មោះ[redacted] ម៉េងធី បានប្រាប់មកខ្លួនថា: លោកអភិបាលស្រុកមិនឱ្យឈូសឆាយដីនោះទេ ព្រោះដីនេះប៉ះពាល់ជាមួយគម្របដីព្រៃឈើ ដោយខ្លួនប្រាប់វិញថា: ចាំអញទៅដោះស្រាយ ដោយខ្លួននៅតែបន្តឈូសដដែលពីព្រោះការហាមឃាត់នោះមិនមានអាជ្ញាធរចេញលិខិតណែនាំ ឬអញ្ជើញខ្លួនលើបញ្ហាដែលពាក់ព័ន្ធជាមួយការឈូសឆាយដីនោះទេ គឺគ្រាន់តែប្រាប់តាមរយៈឈ្មោះ[redacted] ម៉េងធី ដោយមាត់ទទេប៉ុណ្ណោះ។ ចំពោះដីនេះ គឺខ្លួនបានទិញពីប្រជាជនដោយមានអាជ្ញាធរភូមិឃុំស្រុកចុះហត្ថលេខាទទួលស្គាល់។ ម្យ៉ាងវិញទៀត ខ្លួនគិតថាការឈូសឆាយសម្រួលផ្លូវនេះដើម្បីទុកសម្រាប់បម្រើឱ្យ



Scanned with CamScanner

ផលប្រយោជន៍រួម ប្រសិនបើដឹងថាដីនោះជាដីរបស់រដ្ឋ ខ្លួនក៏មិនហ៊ានឈូសឆាយផ្លូវនេះដែរ។ ចំពោះដីទាំងអស់នោះ គឺបានចុចGPSពីមន្ត្រីសុរិយោដីរួចហើយ ដោយមានការកំណត់ព្រំដីយ៉ាងច្បាស់លាស់នូវទំហំដី ២៩៨ហិចតា។ រីឯឈ្មោះ [redacted] សុធារ៉ាន់ គ្រាន់តែជាអ្នកណែនាំឱ្យខ្លួនស្គាល់ឈ្មោះ [redacted] ឈិន ដើម្បីយកប្រាក់កម្រៃជើងសារពីខ្លួនតែប៉ុណ្ណោះ។ ហើយដីនោះមានការដាំដើមស្វាយចន្ទី និងធូរ៉េន។ ខ្លួនបានធ្វើការឈូសឆាយនោះតាំងពីខែកុម្ភៈ ឆ្នាំ២០២០ រហូតដល់ខែកញ្ញា ឆ្នាំ២០២០ ទើបមានការបង្ក្រាប។

២-ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ាន់ បានឆ្លើយបញ្ជាក់ថា: ខ្លួនបានស្គាល់ឈ្មោះ [redacted] ធី ដោយចែដន្យនៅក្នុងឆ្នាំ២០០៩ និងធ្វើការរាប់អានគ្នាជាមិត្តភក្តិ។ កន្លងមកខ្លួនធ្លាប់បានទិញដីពីឈ្មោះ [redacted] ធី ចំនួន ៦០ហិចតា ក្នុងតម្លៃ ៨០០ដុល្លារអាមេរិក នៅក្រៅតំបន់ដីដែលមានបញ្ហានេះ។ លុះក្រោយមកក្នុងឆ្នាំ២០២០ ឈ្មោះ [redacted] ធី បានប្រាប់មកខ្លួនថាគេមានដីទំហំ២៩៨ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដោយសុំឱ្យខ្លួនរកអ្នកទិញ ឬរកដៃគូមកវិនិយោគ ហើយឈ្មោះ [redacted] ធី បានសន្យាថានឹងឱ្យកម្រៃជើងសារមកខ្លួនចំនួន ៣០% នៅពេលរកដៃគូសហការបាន និងប្រាប់ខ្លួនថាមិនចាំបាច់ធ្វើសកម្មភាពឬផ្តល់ជាគំនិតយោបល់អ្វីទាំងអស់។ ចំពោះដីដែលឈ្មោះ [redacted] ធី បានប្រាប់មកខ្លួននោះ គឺខ្លួនមិនបានដឹងថាដីទាំងនោះមានជាប់ពាក់ព័ន្ធជាមួយដីតម្រូបព្រៃឈើ ឬដីរបស់រដ្ឋនោះទេគ្រាន់តែដឹងថាដីទាំងនោះ គឺឈ្មោះ [redacted] ធី បានមកពីការទិញលក់ពីប្រជាជនដោយមានរដ្ឋអំណាចទទួលស្គាល់ពីភូមិឃុំស្រុក និងមិនមានការទទួលស្គាល់ពីសុរិយោដីនោះទេ រួចខ្លួនក៏មិនបានដេញដោលលម្អិតអំពីដីនោះដែរ។ បន្ទាប់មកខ្លួនបានប្រាប់ពីគម្រោងអភិវឌ្ឍន៍នេះទៅឈ្មោះលី បញ្ញាភា ហើយគេបាននាំខ្លួនឱ្យស្គាល់ឈ្មោះ [redacted] ឈិន ដែលជាអ្នកចង់វិនិយោគ និងឈានដល់ការចុះកិច្ចសន្យារវាងម្ចាស់ដីគឺឈ្មោះ [redacted] ធី និងអ្នកវិនិយោគឈ្មោះ [redacted] ឈិន ទើបឈានដល់ការបង្កើតលក្ខន្តិកៈក្រុមហ៊ុនដែលមានឈ្មោះ [redacted] ធី ជាប្រធានក្រុមហ៊ុន និងឈ្មោះ [redacted] ឈិន ជាអគ្គនាយក ចំណែកខ្លួន, ឈ្មោះ [redacted] បញ្ញាភា និងឈ្មោះ [redacted] ធូន គឺជាសមាជិកនៃក្រុមហ៊ុន។ ចំពោះមូលហេតុដែលមានឈ្មោះខ្លួននៅការបង្កើតលក្ខន្តិកៈក្រុមហ៊ុន គឺដើម្បីរក្សាកម្រៃជើងសាររបស់ខ្លួន និងការពារពីការឆបោកតែប៉ុណ្ណោះ។ ខ្លួនបានដឹងថា ឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ឈិន បានធ្វើកិច្ចសន្យាដោយឈ្មោះ [redacted] ធី ជាភាគីម្ចាស់ដី និងឈ្មោះ [redacted] ឈិន ជាភាគីអភិវឌ្ឍន៍។ រីឯ ការងារផ្ទៃក្នុងរវាងឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ឈិន គឺខ្លួនមិនបានដឹងទេ។ ខ្លួនមានមុខងារជាអនុប្រធាននាយកដ្ឋាននៅក្រសួងមហាផ្ទៃ។ ខ្លួននឹងទទួលបានប្រាក់កម្រៃជើងសារជាក់លាក់ ចំនួន ៣០% ពីភាគីម្ចាស់ដីឈ្មោះ [redacted] ធី។ ក្រោយពេលបង្កើតលក្ខនិកៈក្រុមហ៊ុនរួចមក ខ្លួនបានចុះទៅមើលទីតាំងវិនិយោគចំនួន ០២ដង ដោយលើកទី១ ខ្លួនបានឃើញមានការដាក់ស្វូឡា មានការដាំដុះដំណាំ និងវាលស្មៅ និងមិនមានការឈូសឆាយនោះទេ និងលើកទី២ ខ្លួនបានឃើញខ្មួមសម្រាប់ជ្រកធ្វើការ។ ចំពោះការអភិវឌ្ឍន៍ដី និងការលើកគម្រោងក្នុងការលក់ដូរដីនោះ គឺខ្លួនមិនបានដឹងទេ ហើយខ្លួនបានធ្វើជាសាក្សីក្នុងកិច្ចសន្យារវាងឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ឈិន គឺដើម្បីតែផលប្រយោជន៍កម្រៃជើងសារប៉ុណ្ណោះដោយខ្លួនមិនបានបញ្ចេញយោបល់ ឬដាក់ភាគហ៊ុនចេញជាប្រាក់កាសជាមួយឈ្មោះចាន់ ធី និងឈ្មោះ [redacted] ឈិន លើដីនោះទេ។

៣-ជនជាប់ចោទឈ្មោះ [redacted] ឈិន បានឆ្លើយបញ្ជាក់ថា: ខ្លួនមានមុខរបរជាប្រធានក្រុមហ៊ុន LPRO សឡា។ ខ្លួនមិនមានជំនាញទីផ្សារផ្នែកអចលនទ្រព្យនោះទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ធី តាមរយៈឈ្មោះ [redacted] បញ្ញាភា ហើយឈ្មោះ [redacted] បញ្ញាភា បានប្រាប់ខ្លួនថាបានពត៌មានពីឈ្មោះ [redacted] សុធារ៉ាន់ ថាឈ្មោះ [redacted] ធី មានដីចង់អភិវឌ្ឍន៍ទំហំ ២៩៨ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។ ក្រោយមកខ្លួនបានចុះទៅមើលទីតាំងនោះដោយមិនមានរដ្ឋអំណាចមូលដ្ឋានចូលរួមទេ ហើយឈ្មោះ [redacted] ធី បានបង្ហាញឯកសារពាក់ព័ន្ធ និងដីមានចុះហត្ថលេខាដោយមេភូមិមេឃុំដាក់ដាំ តែមិនមានការទទួលស្គាល់ដោយសុរិយោដីនោះទេ ។ ម៉្យាងវិញទៀតឈ្មោះ [redacted] ធី បានអះអាងថាដីទាំងអស់ គឺជាកម្មសិទ្ធរបស់គាត់ដែលទិញពីប្រជាពលរដ្ឋ និងធានាលើការរត់ការសម្របសម្រួលផ្លូវច្បាប់ព្រមទាំងធានាលើការឈូសឆាយដីឱ្យខ្លួន ដោយខ្លួនគ្រាន់តែទទួលខុស

ត្រូវលើប្រតិបត្តិការចំណាយលើការអភិវឌ្ឍន៍ប៉ុណ្ណោះ។ ក្រោយមកនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ ខ្លួនបានចុះកិច្ចព្រមព្រៀងគ្នាជាមួយឈ្មោះ[redacted] ធី លើការវិនិយោគដីទំហំ២៨៩ ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី។ ចំពោះកិច្ចសន្យាវិនិយោគដីនេះ គឺមានភាគីម្ចាស់ដីឈ្មោះ[redacted] ធី ចំណែកឯភាគីខាងវិនិយោគរួមមានខ្លួន, ឈ្មោះ[redacted] ធូន, ឈ្មោះ[redacted] បញ្ញាភា និងឈ្មោះ[redacted] សុធារ៉ាន់ ដោយក្នុងកិច្ចព្រមព្រៀងនោះឈ្មោះ[redacted] ធីមានភាគហ៊ុនចំនួន៦០% ជាភាគីម្ចាស់ដី និងភាគីខ្លួនជាអ្នកវិនិយោគមានភាគហ៊ុនចំនួន ៤០%។ ខ្លួនមិនបានដឹងថាដីទំហំ ២៩៨ ហិចតា មានការពាក់ព័ន្ធជាមួយបរិស្ថាន និងគម្របព្រៃឈើនោះទេ លើសពីនេះទៅទៀតប្រសិនខ្លួនដឹងថាដីនេះមានបញ្ហានោះ ខ្លួនក៏មិនចុះកិច្ចសន្យាអភិវឌ្ឍន៍ជាមួយឈ្មោះ[redacted] ធី នោះដែរ។ ទាំងនេះដោយមានការទុកចិត្តគ្នាជាមួយឈ្មោះ[redacted] ធី ទើបឈានដល់មានការចុះកិច្ចសន្យារវាងម្ចាស់ដីឈ្មោះ[redacted] ធី និង ខ្លួនគឺជាអ្នកអភិវឌ្ឍន៍ ដោយមានឈ្មោះ[redacted] បញ្ញាភា និងឈ្មោះ[redacted] សុធារ៉ាន់ ធ្វើជាសាក្សីក្នុងកិច្ចសន្យានោះ។ ក្រោយមកបានបង្កើតលក្ខន្តិកៈក្រុមហ៊ុនដាក់ដាំអិនវេសមែន ដោយមានឈ្មោះ[redacted] ធី ជាប្រធានក្រុមប្រឹក្សាភិបាល, ខ្លួនជាអគ្គនាយក,ឈ្មោះ[redacted] សុធារ៉ាន់,ឈ្មោះ[redacted] ធូន និងឈ្មោះ[redacted] បញ្ញាភា ជាសមាជិកដោយលក្ខន្តិកៈក្រុមហ៊ុនមិនមានចុះបញ្ជីត្រឹមត្រូវនោះទេ។ ចំពោះឈ្មោះ[redacted] សុធារ៉ាន់ យកកម្រៃជើងសារពីម្ចាស់ដីឈ្មោះ[redacted] ធី ចំណែកឯឈ្មោះ[redacted] បញ្ញាភា និងឈ្មោះ[redacted] ធូន បានកម្រៃជើងសារពីខ្លួនចំនួន ១៣% ក្នុងម្នាក់ៗ។ ខ្លួនសូមបញ្ជាក់ថាអ្នកដែលទទួលបានកម្រៃជើងសារទាំងបីនាក់ គឺមិនបានចេញប្រាក់កាក់ និងមានភាគហ៊ុននៅក្នុងកិច្ចសន្យានោះឡើយ។ ការចាប់ផ្តើមគម្រោងអភិវឌ្ឍន៍នៅអំឡុងខែមេសា ឆ្នាំ២០១៩ គឺធ្វើឡើងបន្ទាប់ពីការចុចGPSវាស់ពីទំហំដីត្រឹមត្រូវរួចពីមន្ត្រីសុរិយោដី។ កន្លងមកខ្លួនបានចំណាយប្រាក់លើការជីកអណ្តូងទឹក, សង់រោងកាហ្វេ, ដាក់អំពូលសូឡា ដែលសរុបទឹកប្រាក់អស់ចំនួន ២ម៉ឺនដុល្លារអាមេរិក នាខណៈពេលដែលខ្លួនធ្វើលើដីនោះ គឺមិនមានអាជ្ញាធរមកហាមឃាត់នោះទេ។ លុះដល់អំឡុងឆ្នាំ២០២០ ខ្លួនបានលក់ដីក្នុងគម្រោងនេះចំនួន ០៦ហិចតា ដែលដីទាំងនេះមានសណ្ឋានជាដីវាលស្មៅធម្មតាទៅឱ្យអតិថិជន ចំនួនបីនាក់ដោយអ្នកទិញលក់ ចុះហត្ថលេខាត្រឹមថ្នាក់ភូមិឃុំ និងមិនទាន់មានចុះហត្ថលេខាដល់ស្រុកនៅឡើយទេ។ លុះដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ០៩ [redacted] ព្រឹក នាខណៈពេលដែលសមត្ថកិច្ចចុះបង្ក្រាបនោះ គឺមិនមានសកម្មភាពឈូសឆាយលើដីនោះទេ។ ចំពោះការសង់រោងស[redacted] លើដីនោះ គឺខ្លួនទិញឈើពីអ្នកភូមិយកមកសាងសង់នោះទេ។ ខ្លួនស្គាល់ឈ្មោះ[redacted] ជុន និងឈ្មោះ[redacted] សំណាង ដែលអ្នកទាំងពីរបានមានវត្តមានលើដីនោះ។ ក្រៅពីនេះ ខ្លួនមិនស្គាល់អ្នកណានោះទេ។

៤-ជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា បានឆ្លើយបញ្ជាក់ថា: ខ្លួនស្គាល់ឈ្មោះចាន់ ធី តាមរយៈឈ្មោះ[redacted] សុធារ៉ាន់ ហើយឈ្មោះ[redacted] សុធារ៉ាន់ បានប្រាប់មកខ្លួនថាឈ្មោះ[redacted] ធី មានដីទំហំ ២៩៨ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ដែលជាដីស្របច្បាប់របស់ឈ្មោះ[redacted] ធី។ បន្ទាប់មកខ្លួនបានចុះទៅមើលទីតាំងដីឃើញឈ្មោះ[redacted] ធី មានប្លង់ឌីម៉ាស់ និងឯកសារផ្សេងៗដែលគាត់បានទិញដីនោះក្នុងអំឡុងឆ្នាំ២០០៦ និងឆ្នាំ២០០៧ ដោយដីនោះមិនមានការពាក់ព័ន្ធជាមួយដីរបស់រដ្ឋដោយឈ្មោះ[redacted] ធី បង្ហាញពីលិខិតស្នាមត្រឹមត្រូវបញ្ជាក់ថាដីទាំងនោះដីស្របច្បាប់ ទើបខ្លួនណែនាំទៅឈ្មោះ[redacted] ឈិន។ នៅថ្ងៃទីមិនចាំខែមេសា ឆ្នាំ២០២០ ឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ឈិន បានចុះកិច្ចសន្យាព្រមព្រៀង ដោយឈ្មោះ[redacted] ធី ជាភាគីម្ចាស់ដី និងឈ្មោះ[redacted] ឈិន ជាភាគីម្ខាងទៀត។ រីឯខ្លួន និងឈ្មោះ[redacted] សុធារ៉ាន់ គ្រាន់តែជាសាក្សីដោយខ្លួនជាសាក្សីឱ្យឈ្មោះ[redacted] ឈិន ហើយឈ្មោះ[redacted] សុធារ៉ាន់ ជាសាក្សីឱ្យឈ្មោះ[redacted] ធី។ បន្ទាប់មកពួកខ្លួនបានបង្កើតលក្ខន្តិកៈក្រុមហ៊ុនហ្វូណេសាន ដោយលក្ខន្តិកៈក្រុមហ៊ុនមិនទាន់បានចុះបញ្ជី ក្នុងនោះមានឈ្មោះ[redacted] ធី ជាប្រធានក្រុមប្រឹក្សាភិបាល និងមានឈ្មោះ[redacted] ឈិន ជាអគ្គនាយក ហើយឈ្មោះ[redacted] សុធារ៉ាន់, ឈ្មោះសាង ធូន និងឈ្មោះ [redacted] បញ្ញាភា គឺជាសមាជិក។ មូលហេតុដែលខ្លួនជាសមាជិកនៅក្នុងលក្ខន្តិកៈក្រុមហ៊ុននោះ គឺការពារក្នុងការទទួលបានកម្រៃជើងសារ១៣%លើការណែរវាងឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ឈិន ដោយខ្លួនយកពីឈ្មោះ[redacted] ឈិន តែមិនទាន់បានទទួលកម្រៃជើងសារនៅឡើយទេ។ នៅ

ពេលនោះ មានការចេញចូលនៅតំបន់ដីនោះ គឺគ្មានអាជ្ញាធរណាម្នាក់មកហាមឃាត់នោះទេ។ បន្ទាប់មកខ្លួនបានជួយលក់បានដីមានអ្នកទិញបីម្ចាស់នូវដីចំនួន០៦ហិចតា លើផ្ទៃដីវាលដែលមិនមានព្រៃនោះក្នុងតម្លៃ៣ម៉ឺនដុល្លារអាមេរិកក្នុងមួយហិចតាដោយទទួលប្រាក់កក់ចំនួន ១០% ដោយខ្លួនបានប្រគល់ប្រាក់នោះឲ្យទៅឈ្មោះ[redacted] ឈិន។ ចំពោះការឈូសឆាយសម្រួលផ្លូវថ្នល់ជាកាតព្វកិច្ចរបស់ម្ចាស់ដីឈ្មោះ[redacted] ធី ហើយការឈូសឆាយសម្រួលផ្លូវនោះ គឺដើម្បីសម្រួលដល់ការចេញចូលរបស់ប្រជាជនដោយមិនមានអាជ្ញាធរណាម្នាក់មកហាមឃាត់ឡើយហើយខ្លួនក៏មិនបានដឹងពីការឈូសឆាយនោះទេ។

៥-ជនជាប់ចោទឈ្មោះ[redacted] ធួន បានឆ្លើយបញ្ជាក់ថា: ខ្លួនបានស្គាល់ឈ្មោះ[redacted] បញ្ញាភា ព្រោះធ្លាប់ជាអ្នកធ្វើការជាមួយគ្នា ហើយឈ្មោះ[redacted] ឈិន គឺជាអ្នកធ្វើការរួមអាជីបជាមួយគ្នាក្នុងឆ្នាំ២០១៥។ ខ្លួនជាបុគ្គលិកផ្នែកអចលនទ្រព្យ ទើបឈ្មោះ[redacted] ឈិន និងឈ្មោះ[redacted] បញ្ញាភា បានហៅខ្លួនចូលរួមក្នុងការវិនិយោគនៅលើដីទំហំ ២៩៨ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដោយខ្លួនបានដាក់ឈ្មោះធ្វើជាសមាជិកក្នុងលក្ខន្តិក:ក្រុមហ៊ុន(មិនទាន់ចុះបញ្ជី) ក្នុងគោលបំណងដើម្បីទទួលបានកម្រៃជើងសារចំនួន ១៣% ពីឈ្មោះ[redacted] ឈិន។ ខ្លួនមិនបានដឹងថា ដីនោះជារបស់អ្នកណាទេ និងមានការពាក់ព័ន្ធជាមួយដីរដ្ឋ ឬយ៉ាងណា គឺខ្លួនមិនដឹងទេហើយខ្លួនក៏មិនបានធ្វើជាសាក្សីក្នុងកិច្ចសន្យានោះដែរ។ ខ្លួនធ្លាប់ទៅទីតាំងដីនោះបានចំនួនបីដង ហើយខ្លួនមានតួនាទីជាអ្នកទីផ្សារនៅក្នុងគម្រោងលក់ដីនោះ តែខ្លួនមិនទាន់បានលក់ដីបានមួយប្លង់ទេ។ ចំពោះការលក់ដីបីប្លង់នោះ គឺឈ្មោះ[redacted] ឈិន និងឈ្មោះ[redacted] បញ្ញាភា ជាអ្នកលក់ ហើយខ្លួនក៏មិនទាន់ទទួលបានកម្រៃជើងសារទេ ពីព្រោះខ្លួនមិនទាន់រកម៉ូយលក់ដីនោះបាននៅឡើយ។ ខ្លួនមិនបានដឹងអំពីការឈូសឆាយដីព្រៃនោះទេ។

៦-ជនជាប់ចោទឈ្មោះ[redacted] ម៉េងធី បានឆ្លើយបញ្ជាក់ថា:ខ្លួន គឺជាអ្នកសារពត៌មាននៅខេត្តមណ្ឌលគិរី។ ខ្លួនដឹងថាឈ្មោះ[redacted] ធី មានដីនៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។ ចំពោះទំនាក់ទំនងរវាងឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ឈិន គឺខ្លួនមិនបានដឹងទេ ហើយការចុះកិច្ចសន្យារវាងភាគីទាំងពីរនោះក៏ខ្លួនមិនបានដឹងដែរ។ ចំពោះ ឈ្មោះ[redacted] ឈិន បានទៅដាក់បង្គោលសឡា និងសង់ផ្ទះលើដីទំហំ ២៩៨ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ក៏ខ្លួនមិនបានដឹងនោះដែរ។ ខ្លួនធ្លាប់ទៅទីតាំងដីចំនួនពីរដង ដោយសារលោកអភិបាលស្រុកអូររាំងឈ្មោះ[redacted] មុន្នី បានឲ្យខ្លួនចូលទៅមើលទីតាំងដីឈូសឆាយជាប់កន្លែងកើតហេតុ។ នៅថ្ងៃមិនចាំខ្លួនពិតជាបានប្រាប់ទៅឈ្មោះ[redacted] ធី ថាលោកអភិបាលស្រុកមិនអនុញ្ញាតឲ្យឈូសឆាយដីនោះទេ ប៉ុន្តែឈ្មោះ[redacted] ធី បានឆ្លើយថា “អញដឹងហើយចាំអញទៅជួបចៅហ្វាយស្រុក” នាខណ:ពេលដែលខ្លួនបានប្រាប់ឈ្មោះ[redacted] ធី នោះ គឺខ្លួនឃើញមានវត្តមានឈ្មោះ[redacted] ម៉ាប់, ឈ្មោះ[redacted] សុខា, ឈ្មោះ[redacted] ចិន្តា, ឈ្មោះ[redacted] សុភក្តិ, ឈ្មោះ[redacted] ជុង, ឈ្មោះ[redacted] សំណាង និងឈ្មោះ[redacted] សារឿន។ ខ្លួនមិនបានទទួលប្រាក់កាក់ពីឈ្មោះ[redacted] ធី នោះទេ តែឈ្មោះ[redacted] ធី ធ្លាប់បាននិយាយថា: ចាំគាត់ឲ្យដីប្អូនទៅដប់ម៉ែត្រមកខ្លួនសម្រាប់ធ្វើផ្ទះដោយការសន្យានេះមិនមានការពាក់ពន្ធ័ជាមួយការមិនចុះផ្សាយនោះទេ។ ចំណែកឯសកម្មភាពរបស់ឈ្មោះ[redacted] ធី ធ្វើការឈូសឆាយផ្លូវនេះ គឺគ្រាន់តែសម្រួលលើផ្លូវចាស់ដើម្បីឲ្យមានភាពងាយស្រួលឲ្យប្រជាជនធ្វើដំណើរតែប៉ុណ្ណោះ។

៧-ជនជាប់ចោទឈ្មោះ[redacted] ជុង បានឆ្លើយបញ្ជាក់ថា: កាលពីឆ្នាំ២០០៦ ខ្លួន គឺជាអ្នកទិញដីឲ្យឈ្មោះ[redacted] ធី ដោយបានដើរប្រមូលទិញដីពីឈ្មោះ[redacted] វន, ឈ្មោះ[redacted] សុធា និងឈ្មោះ[redacted] ស៊ុនហ៊ន់ ក្នុងតម្លៃ ៦ពាន់ដុល្លារអាមេរិក និងបានទិញចំនួនបីភ្នំ នៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ក្នុងអំឡុងឆ្នាំ២០០៦ និងឆ្នាំ២០០៧។ ខ្លួនបានដឹងថាឈ្មោះ[redacted] ធី មានដីនៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដោយដីនោះបានទិញដីពីប្រជាពលរដ្ឋ ប៉ុន្តែមិនបានដឹងថាមានឯកសារអ្វីខ្លះនោះទេ។ ប៉ុន្តែខ្លួនមិនដឹងពីគម្រោងអភិវឌ្ឍន៍ និងការចុះកិច្ចសន្យាការអភិវឌ្ឍន៍លើដីនោះរវាងឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ឈិន នោះទេ ហើយខ្លួនស្គាល់តែឈ្មោះ[redacted] ធី និងឈ្មោះ[redacted] សុធារ៉ាន់។ លោកស្នងការរងទទួលបន្ទុកព្រំដែនឈ្មោះ[redacted] ចិន្តា ពិតជាបានឲ្យខ្លួនទៅមើលដីនោះតើមានអ្នកណាធ្វើអ្វីដោយខ្លួនទៅមើលដីនោះដោយខ្លួនទៅ

តាមបញ្ជារបស់ស្នងការរង ហើយពេលចុះទៅដល់ខ្លួនបានឃើញឈ្មោះ[redacted] សុធារ៉ាន់ និងឈ្មោះ[redacted] ធី នៅជាមួយគ្នា និងបានឮអ្នកទាំងពីរនិយាយគ្នាអំពីការអភិវឌ្ឍន៍គម្រោងលើដីនោះ។

៨-ជនជាប់ចោទឈ្មោះ[redacted] សុខេង បានឆ្លើយបញ្ជាក់ថា: ខ្លួន គឺជាប្រធានការិយាល័យភូមិបាលស្រុកអូររាំង។ ខ្លួនមិនស្គាល់ឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ឈិន ព្រមទាំងមិនបានដឹងពីគម្រោងអភិវឌ្ឍដីនៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី នោះទេ។ ចំពោះដី ៦ហិចតានៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី នោះ គឺមន្ត្រីឈ្មោះ[redacted] វណ្ណារ័ត្ន ជាអ្នកចុះទៅវាស់វែងចុច GPS ដោយគាត់ជាមន្ត្រីជំនាញហើយការចុះទៅវាស់វែង គឺខ្លួនមិនបានដឹងនោះទេ។ ចំណែកឯការវាស់វែងរួច គឺឈ្មោះ[redacted] វណ្ណារ័ត្ន បានចុះហត្ថលេខា និងបានបញ្ជូនឯកសារទាំងនោះឱ្យមកខ្លួនដើម្បីពិនិត្យ និងចុះហត្ថលេខាដោយមានអមជាមួយឯកសារណាបដែលមានចុះហត្ថលេខាភូមិឃុំ និងមានការបញ្ជាក់អំពីទំហំ និងព្រំដីចំនួន៦ហិចតានោះ។ ខ្លួនមិនបានចុះទៅមើលទីតាំងមុនពេលចុះហត្ថលេខានោះទេ ហើយខ្លួនក៏បានមិនដឹងថាដីទាំងនោះជារបស់រដ្ឋនោះទេ។ ប្រសិនបើដីទំហំ ៦ហិចតានោះមានការពាក់ព័ន្ធជាមួយដីរដ្ឋ ឬដីគម្របព្រៃឈើនោះ គឺខ្លួនមិនចុះហត្ថលេខានោះទេ។ ការចុះហត្ថលេខារបស់ខ្លួនលើដីទំហំ ៦ហិចតា មានបីប័ណ្ណនោះ គឺមានការវាស់វែងចុច GPS ត្រឹមត្រូវយោងតាមការចុះហត្ថលេខា និងបោះត្រាលើការស្នើសុំរបស់ឈ្មោះ[redacted] វណ្ណារ័ត្ន ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់នានាជាឯកសារណាបចុះហត្ថលេខាដោយអាជ្ញាធរភូមិឃុំ ក្នុងឆ្នាំ២០០៦-២០០៧។ ម្យ៉ាងវិញទៀត ការកត់សម្គាល់ក្នុងប្លង់ឌីម៉ាស់ នៃការវាស់វែងនោះ គឺមានទម្រង់ច្បាស់លាស់ដោយបានបញ្ជាក់ដែរថា: ការចុះហត្ថលេខារបស់មន្ត្រីសុរិយោដី គឺគ្រាន់តែបញ្ជាក់ពីទំហំដី ហើយប្រសិនបើដីនោះមានការប៉ះពាល់ជាមួយដីរដ្ឋ គឺភាគីម្ចាស់ដីជាអ្នកទទួលខុសត្រូវ។

៩-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ សាកសួរនៅក្រុមស៊ើបសួរ នៃសាលាដំបូងខេត្តក្រចេះ បានឆ្លើយបញ្ជាក់ថា: ខ្លួនមានតួនាទីជាអនុប្រធានការិយាល័យសុរិយោដី និងភូមិសាស្ត្រ នៃមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តមណ្ឌលគីរី តាំងពីអំឡុងឆ្នាំ២០០៥ រហូតដល់បច្ចុប្បន្ន។ ចំពោះទំនាក់ទំនងខ្លួនជាមួយឈ្មោះ[redacted] ធី គឺខ្លួនមិនស្គាល់ទេ។ ក្នុងរឿងនេះដំបូងឡើយ គឺមានឈ្មោះ ម៉េងធី និងមនុស្សស្រីម្នាក់បានមកទំនាក់ទំនងសុំឱ្យខ្លួនជួយទៅវាស់ដីដោយគេចង់ដឹងទំហំដី ចង់ដឹងថាមានជាន់ជាមួយគេឬអត់ ដោយអ្នកស្នើសុំមានបង្ហាញពាក្យស្នើសុំ[redacted] កាន់កាប់មានហត្ថលេខាពីភូមិឃុំ និងឯកសារខ្លះទៀតចុះហត្ថលេខាដល់ស្រុក។ ខ្លួនបានទៅទីតាំងដីនោះជាមួយឈ្មោះ[redacted] ធី ហើយគាត់ជាអ្នកចង្អុលបង្ហាញព្រំដីទាំងបីកន្លែងឱ្យខ្លួនវាស់វែងដោយម្ចាស់ដីស្នើសុំវាស់វែងចំនួន បីប្លង់ដោយតាមការចង្អុលបង្ហាញពីម្ចាស់ដីហើយខ្លួនបានតំឡើងផែនទី គឺត្រូវជាមួយនឹងភូមិឃុំនៅក្នុងប្លង់ គឺភូមិពូឆប ឃុំដាក់ដាំ តែត្រង់ចំណុចកន្លែងណា គឺខ្លួនអត់ដឹងទេដោយនៅក្នុងប្លង់ចាស់របស់ម្ចាស់ដីអត់មាននិយាមការ។ នៅពេលដែលខ្លួនចុចជីភីអេសដែលមាននិយាមការច្បាស់លាស់ គឺពុំដឹងថាតំបន់នេះស្ថិតនៅតំបន់អភិរក្សបរិស្ថាន ឬគម្រប់ព្រៃឈើរបស់ក្រសួងកសិកម្មនោះដែរ ដោយខាងខ្លួនពុំមានទិន្នន័យទាំងនេះទេ។ ខ្លួនបានចុះហត្ថលេខាលើគំនូសបង្ហាញទីតាំង និងសណ្ឋានដី គឺអះអាងបញ្ជាក់ទីតាំងដី និងទំហំដីនៅទីតាំងនោះ គឺផែកមើលផែនទីដែលផ្តល់ដោយក្រសួងគឺមានទិន្នន័យផ្លូវលំ ហើយផ្លូវលំគឺទៅដល់កន្លែងដែលខ្លួនវាស់វែង(ជីភីអេស)ហើយការធ្វើគំនូសប្លង់នេះ គឺការពារកុំឱ្យជាន់ដីគ្នា។ ម្ចាស់ដីស្នើសុំឱ្យខ្លួនវាស់វែងដីចំនួនបីប្លង់ ហើយខ្លួនបានវាស់វែង និងបានកាត់ចំណីផ្លូវនៅក្នុងប្លង់នោះដែរ។ នៅពេលដែលខ្លួនបានវាស់វែងរួចគូសចេញប្លង់ និងចុះហត្ថលេខាហើយបានប្រគល់ឱ្យម្ចាស់ដីយកទៅប្រើប្រាស់។ ចំពោះរូបមន្តគំនូសបង្ហាញទីតាំងក្បាលដី និងរូបសណ្ឋានកន្លែងជ្រុងក្បាលដី គឺខាងមន្ទីររបស់ខ្លួនជាអ្នកបន្ថែមកំណត់សម្គាល់នៅរឹមទំព័រខាងក្រោយថាគំនូសប្លង់នេះបញ្ជាក់អំពីទីតាំង និងទំហំដីតែប៉ុណ្ណោះមិនមែនបញ្ជាក់ថានៅក្រៅផែនទីគម្របព្រៃដែនការពារ ឬសម្បទានដីសេដ្ឋកិច្ចផ្សេងៗឡើយ និងរាល់ផលប៉ះពាល់លើទីតាំងដីជាការទទួលខុសត្រូវរបស់ម្ចាស់ដី។ ចំណែកឯការណែនាំរបស់ក្រសួងដែនដីតាមលិខិតលេខ១៩៧៤ដនស/អសដក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ នោះឱ្យ

រដ្ឋបាលឃុំសង្កាត់ និងរដ្ឋបាលស្រុកខណ្ឌបញ្ឈប់ការពិនិត្យ និងបញ្ជាក់លើឯកសារផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីណាដែលពុំមានភ្ជាប់គំនូសប្លង់ទីតាំងមាននិយាមការ ច្បាស់លាស់បញ្ជាក់ទទួលស្គាល់ដោយរដ្ឋបាលសុរិយោដី។ ពេលដែលចុះដល់ទីតាំង គឺពុំមានព្រៃទេ គឺមានតែភ្នំ និងវាលស្មៅមានដើមស្រល់ ៤ ទៅ១០ដើម និងដើមស្វាយចន្ទីប្រហែល២០ ទៅ៣០ដើម ហើយមើលសភាពទៅឃើញការដាំយូរហើយ ហើយនៅខាងក្រោយដីនោះប្រហែល១០០ ទៅ២០០ម៉ែត្រ មានព្រៃក្រាស់ចូលមិនចុះទេ។ ខាងក្រសួងដែនដីធ្លាប់បានណែនាំកុំឱ្យវាស់វែងដីព្រៃ ហើយកន្លែងដែលខ្លួនចុះវាស់ គឺដីវាលទេ។ ខាងក្រសួងក៏បានផ្តល់ផែនទីតាមមន្ទីររាជធានីខេត្តដែលផែនទីនោះបង្ហាញពីទំហំដីកំណត់ទំហំផ្លូវ ចំណីផ្លូវ និងចំណីអូរច្បាស់លាស់។ ការចុះទៅវាស់ គឺចុះអំឡុងខែមីនា ឆ្នាំ២០២០ ហើយទីតាំងដីនោះពុំទាន់មានធ្វើអ្វីទេ ហើយផ្លូវក៏ពុំទាន់បានឈូសឆាយដែរ គឺផ្លូវចាស់ជិតមួយខែក្រោយមកទើបធ្វើប្លង់រួច ។ ដីនោះ គឺចុះពីផ្លូវជាតិប្រហែល២ គីឡូម៉ែត្រ ដល់ដីនោះ គឺមើលឃើញខាងវៀតណាម។

១០-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ[redacted] សុភក្តិ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តក្រចេះ បានឆ្លើយបញ្ជាក់ថា: ខ្លួនជានាយរងខណ្ឌរដ្ឋបាលព្រៃឈើខេត្តមណ្ឌលគិរី តាំងពីឆ្នាំ២០១៧ រហូតដល់បច្ចុប្បន្ន។ ចំពោះទំនាក់ទំនងខ្លួនជាមួយឈ្មោះ[redacted] ធី គឺខ្លួនស្គាល់ដោយរាប់អានគ្នាធម្មតាហើយខ្លួនធ្លាប់ទៅទីតាំងដីនៅចំណុចភ្នំរហាំងបានចំនួន ០៣ដង ជាមួយឈ្មោះ[redacted] សុខា, ឈ្មោះ[redacted] ស្ទូ និងឈ្មោះ[redacted] ម៉ាប់។ ខ្លួនបានទៅទីតាំងដីនោះដើម្បីទៅលេង និងរកត្រីហូបចុកលេង ដោយឈ្មោះ[redacted] ម៉ាប់ ជាអ្នកហៅខ្លួនទៅដោយដឹងថាទីតាំងដីនោះ គឺជាដីរបស់ឈ្មោះ[redacted] ធី ហើយពេលខ្លះឈ្មោះ[redacted] ធី ក៏គាត់បានហៅខ្លួនទៅដែរ ហើយពេលទៅលើកទីមួយ គឺគេបានឈូសឆាយផ្លូវស្អាត និងបានបំពាក់អំពូលភ្លើងសឡា និងមានកន្លែងអង្គុយលេង មានផ្ទះមួយខ្នងរួចហើយ។ ពេលដែលខ្លួនទៅទីនោះទាំងបីលើក គឺខ្លួនឃើញឈ្មោះ[redacted] ដុង និងឈ្មោះ[redacted] សំណាង ស្នាក់នៅផ្ទះលើដីនោះ។ ខ្លួនពុំបានជួយឈ្មោះ[redacted] ធី ក្នុងការធ្វើសកម្មភាពក្នុងការឈូសឆាយផ្លូវកាប់ឆ្ការព្រៃដើម្បីធ្វើការអភិវឌ្ឍន៍លើដីនោះទេ។ ចំពោះគ្រឿងចក្រឈូសឆាយដីនោះ គឺខ្លួនពុំបានដឹង និងពុំបានគ្រប់គ្រងគ្រឿងចក្រអ្វីទេ។ ក្នុងខែឧសភា ឆ្នាំ២០២០ ខ្លួនពិតជាបានទៅផ្ទះមេភូមិពូឆបជាមួយឈ្មោះ[redacted] ម៉ាប់ និងឈ្មោះ[redacted] ស្ទូ ចំនួនពីរដងដោយយកឯកសារកាន់កាប់ដីដើម្បីឱ្យគាត់ចុះហត្ថលេខាដោយឈ្មោះ[redacted] ស្ទូ ជាអ្នកកាន់ឯកសារជួបជាមួយមេភូមិ។ ការទៅលើកទីមួយបានជួបមេភូមិ ប៉ុន្តែគាត់មិនបានចុះហត្ថលេខាឱ្យទេតែខ្លួនមិនដឹងមូលហេតុអ្វីទេដោយពួកគាត់និយាយភាសារជនជាតិព្នង។ ទៅលើកទីពីរ គឺឈ្មោះ[redacted] ដុង ទៅជាមួយម្នាក់ទៀតកាន់ឯកសារដដែលទៅតែមេភូមិមិនបានចុះហត្ថលេខាឱ្យទេដោយពួកគាត់និយាយភាសារជនជាតិព្នងខ្លួនក៏ត្រឡប់មកវិញ។ មូលហេតុដែលខ្លួនចុះទៅទាំងពីរលើកនេះ គឺដោយសារតែខ្លួនត្រូវសុំថតចម្លងឯកសារកាន់កាប់ដីធ្លីនោះពីមេភូមិពូឆបដើម្បីរាយការណ៍ជូនរដ្ឋបាលព្រៃឈើថ្នាក់កណ្តាលរបស់ខ្លួន។ ប៉ុន្តែការទៅទាំងពីរលើកនោះ គឺពុំបានទទួលឯកសារពី មេភូមិនោះទេដោយមិនបានឃើញគាត់ចុះហត្ថលេខាឱ្យនោះទេ។ ខ្លួនបានដឹងច្បាស់ថា: ដីរបស់ឈ្មោះ[redacted] ធី ដែលខ្លួនបានទៅលេងទាំងបីលើកនោះ គឺជាដីស្ថិតក្នុងច្រករបៀងរបស់ក្រសួងបរិស្ថាន មូលហេតុដែលខ្លួនដឹងច្បាស់លាស់ គឺខ្លួនបានផែកមើលផែនទីមើលឃើញច្បាស់ពេលនោះខ្លួនបានប្រាប់ឈ្មោះ[redacted] ធី ដែរ ហើយក៏ផុតសមត្ថកិច្ចរបស់ខ្លួនផងដែរ។ ចំពោះចម្លើយឈ្មោះ[redacted] ដុង ដែលបានឆ្លើយថាខ្លួន និងឈ្មោះ[redacted] ម៉ាប់ និងឈ្មោះ[redacted] ស្ទូ ឈូសឆាយផ្លូវដល់ចំណុចភ្នំរហាំងនោះ គឺខ្លួនសុំបដិសេធចោលព្រោះខ្លួនពុំបានធ្វើអ្វីលើទីតាំងតំបន់នោះទេ ដោយហេតុថាខ្លួនដឹងថាតំបន់នោះជាតំបន់អភិរក្សរបស់បរិស្ថាន។ ចំពោះចម្លើយរបស់ឈ្មោះចាន់ ធី ដែលបានឆ្លើយថាឱ្យខ្លួនជាមួយឈ្មោះ[redacted] ម៉ាប់ និងឈ្មោះ[redacted] ស្ទូ ជាអ្នកយកគ្រឿងចក្រទៅឈូសឆាយសម្រួលផ្លូវចាស់នៅទីតាំងតំបន់នោះ ដោយគាត់ជាអ្នកចេញប្រាក់ គឺខ្លួនសុំបដិសេធចោលមិនមែនជាការពិតនោះទេ ដោយខ្លួនដឹងច្បាស់ពីទីតាំងនោះជាតំបន់អភិរក្សរបស់បរិស្ថាន។ ទំនាក់ទំនងខ្លួនដែលបានទៅលេង និងមើលទីតាំងតំបន់នោះ គឺដោយសារតែមានការរាប់អានជាមួយឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ម៉ាប់ តែប៉ុណ្ណោះ ហើយខ្លួនមិនមានទំនាក់ទំនងផលប្រយោជន៍អ្វីពីឈ្មោះ[redacted] ធី ទាក់ទងនឹងការអភិវឌ្ឍន៍ដីរបស់គាត់នោះទេ ដោយសារតែខ្លួនក្នុងឆ្នាំ២០១៧

មានតួនាទីជានាយរងខណ្ឌរដ្ឋបាលព្រៃឈើរួចទៅហើយ មិនមានមូលហេតុសមស្របណាមួយដែលឱ្យខ្លួនទៅធ្វើជាកម្មកររបស់គាត់ក្នុងការឈូសឆាយសម្រួលផ្លូវចាស់ពីផ្លូវជាតិរហូតដល់ចំណុចភ្នំរហាំងនោះទេ ហើយមួយទៀតឈ្មោះ[redacted] ធី ក៏មិនបានផ្តល់ចំណែកដីណាមួយនៅតំបន់នោះឱ្យមកខ្លួននោះទេ។

១១-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ[redacted] សុខា ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តក្រចេះ បានឆ្លើយបញ្ជាក់ថា: ខ្លួនជាមន្ត្រីរដ្ឋបាលព្រៃឈើ ឋានៈនាយផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យ តាំងពីឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន។ ចំពោះទំនាក់ទំនងខ្លួនក្នុងរឿងនេះ គឺខ្លួនស្គាល់ និងរាប់អានគ្នាជាមួយឈ្មោះ[redacted] សុភក្តី ដោយបានទៅលេងនៅទីតាំងដីចំណុចភ្នំរហាំងនោះដើម្បីទៅលេង និងមានកម្មវិធីហូបចុក។ម្យ៉ាងទៀតខ្លួនមានភារកិច្ចក្នុងការចុះបញ្ជីដី ខ្លួនពិតជាបានទៅលេងទីតាំងដីនោះចំនួនពីរដង ពិតមែន ដោយទៅលើកទី១ ឈ្មោះ[redacted] សុភក្តី ហៅទៅអាំងត្រីហូបលេង ពេលទៅដល់នោះ គឺបានឃើញគេឈូសផ្លូវពីផ្លូវជាតិមករួចហើយដល់ចំណុចដីភ្នំរហាំងដោយត្រូវបានគេឈូសឆាយរួចទៅហើយ។ តាមខ្លួនដឹងថាដីទាំងនោះ គឺជាដីរបស់ឈ្មោះ[redacted] ធី បានទិញកាលពី១០ឆ្នាំមុន ដោយខ្លួនបានដឹងពីឈ្មោះ[redacted] សុភក្តី ជាអ្នកនិយាយប្រាប់។ នៅពេលខ្លួនទៅ គឺទៅជាមួយឈ្មោះ[redacted] សុភក្តី តែពីរនាក់ទេ ពេលទៅដល់ គឺបានឃើញគេធ្វើផ្ទះ និងសង់រោងនៅលើដីនោះ និងបានឃើញមានការឈូសផ្លូវពីផ្លូវជាតិ និងមានឈូសព្រៃនៅក្បែរនោះបានខ្លះ និងបានឃើញមានកម្មករនៅពីរទៅបីកន្លែង មួយកន្លែងមានមនុស្សពីរទៅបីនាក់ ដោយកម្មករដែលខ្លួនស្គាល់មានឈ្មោះ[redacted] ជុង និងឈ្មោះ[redacted] សំណាង កំពុងតែមើលការខុសត្រូវសង់រោងនៅទីនោះ។ នៅលើកទី២ ខ្លួនទៅជាមួយឈ្មោះ[redacted] សុភក្តី, ឈ្មោះ[redacted] ម៉ាប់ និងឈ្មោះ[redacted] ស្ទួ ដែរដើម្បីទៅមើលថាដីនោះអាចកាត់ឈ្វៀលចេញពីដីក្រុមហ៊ុនបានឬអត់គ្រាន់តែដើរមើលហើយបានអាំងត្រីហូបនៅទីនោះហើយខ្លួនត្រឡប់មកវិញ។ ចំណែកឯឈ្មោះ[redacted] ម៉ាប់ និងឈ្មោះ[redacted] ស្ទួ គ្រាន់តែតាមជូនខ្លួនដើម្បីពិនិត្យទីតាំងដីឱ្យបានច្បាស់លាស់ ហើយពេលទៅដល់ទីតាំងដីនោះ ខ្លួនបានឃើញឈ្មោះស៊ឹម សំណាង និងឈ្មោះ[redacted] ជុង នៅលើដីនោះដែរ។ ក្រោយមកក៏មានខាងថ្នាក់អន្តរក្រសួងដែលមានក្រសួងដែនដី និងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម ចុះមកឈ្វៀលដី និងចុះបញ្ជីដីឱ្យប្រជាពលរដ្ឋ ស្ថិតនៅភូមិពូត្រែង ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ហើយខ្លួនក៏ទៅចុះធ្វើការជាមួយថ្នាក់ជាតិដែលបានមកទីតាំងដីនោះទៀត។ ខ្លួនមិនដែលបានទៅទីតាំងដីនោះជាមួយឈ្មោះ[redacted] ធី នោះទេ ហើយឈ្មោះ[redacted] ធី មិនបានបញ្ជាឱ្យខ្លួនធ្វើអ្វីនៅលើទីតាំងដីនោះទេ ហើយឈ្មោះ[redacted] ធី ក៏ពុំដែលឱ្យចំណែកដីណាមួយមកខ្លួនដែរ។ ខ្លួនទៅដីនោះតែខ្លួនពុំបានដឹងថាជាដីតំបន់អភិរក្សទេ គ្រាន់តែខ្លួនមើលផែនទី គឺដឹងថាតំបន់នោះស្ថិតនៅក្នុងដីសហគមន៍ និងដីក្រុមហ៊ុនទទួលសម្បទាពីរដ្ឋតែខ្លួនភ្លេចឈ្មោះក្រុមហ៊ុនហើយ ។ មូលហេតុដែលខ្លួនចុះទៅមើលដីនោះដើម្បីចង់ដឹងថាអាចឈ្វៀលដីបានឬអត់ដោយសារខ្លួនជាសមាជិកថ្នាក់ខេត្តចុះបញ្ជីដីរដ្ឋ។ ចំពោះចម្លើយឈ្មោះ[redacted] ម៉េងធី ថា: ឃើញខ្លួនមានវត្តមានលើដីនោះក្នុងពេលដែលគ្រឿងចក្រកំពុងឈូសឆាយផ្លូវ គឺមិនពិតនោះទេ ដោយពេលខ្លួនទៅទីតាំងដីនោះលើកទីមួយ គឺផ្លូវបានឈូសឆាយរួចហើយ ។ ចំពោះខ្លួនមានទំនាក់ទំនងជាមួយឈ្មោះ[redacted] ធី លើដីនោះដោយសារតែឈ្មោះ[redacted] ធី បានពឹងខ្លួនឱ្យទៅមើលដីនោះថាតើអាចឈ្វៀលដីនោះចេញពីក្រុមហ៊ុនបានអត់? តែមិនមែនឈ្វៀលចេញរួចឱ្យទៅឈ្មោះ[redacted] ធី នោះទេ គឺខ្លួនប្រមូលទិន្នន័យពីការអាស្រ័យផលជាក់ស្តែង ឬពុំមានអាស្រ័យផលជាក់ស្តែងរបស់អ្នកកំពុងកាន់កាប់ដីដាក់ជូនមន្ទីរដែនដីរួចលើកសំណើរបញ្ជូនទៅអភិបាលខេត្តប្រជុំសម្រេច។ មូលហេតុដែលខ្លួនសម្រេចចុះទៅមើលទីតាំងដីនោះតាមសំណើររបស់ឈ្មោះ[redacted] ធី គឺដោយសារខ្លួនបានកំពុងតែធ្វើការចុះស្រង់ទិន្នន័យកាត់ឈ្វៀលដីជូនប្រជាពលរដ្ឋក្នុងភូមិពូត្រែងជិតរួចអស់ហើយ និងឆ្លងចូលស្រង់ចូលទិន្នន័យកាត់ឈ្វៀលដីជូនប្រជាពលរដ្ឋភូមិពូឆបបន្តទៀត។

ក-សាក្សីឈ្មោះ[redacted] ហ៊ុនអេង បានឆ្លើបញ្ជាក់ថា: ខ្លួនមានតួនាទីជានាយការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល នៅស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី។ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ខ្លួន និងកម្លាំងចម្រុះបានចុះបង្ក្រាបបទល្មើសជាក់ស្តែង

នៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី។ នៅពេលនោះ ខ្លួនមិនបានឃើញមានគ្រឿងចក្រ និងត្រាក់ទ័រអ្វីទេ។ ប៉ុន្តែពិតជាមានការឈូសឆាយផ្លូវបានច្រើន ដោយខ្លួនបានឃើញមានឈ្មោះ[redacted] ឈិន, សង្សារគាត់, ឈ្មោះ[redacted] រតនា និងកម្មករចំនួន ០៥នាក់ទៀត មិនចាំឈ្មោះ នៅកន្លែងកើតហេតុ។ ដីដែលខ្លួនចុះទៅបង្ក្រាបនោះ គឺមានសណ្ឋានជាដីព្រៃជុំវិញ និងឃើញមានការសាងសង់រោងម៉ាស៊ីនធ្វើអំពីក្តារប្រក់ស័ង្កសីចំនួន ០៤, ផ្ទះឈើចំនួនមួយកំពុងសាងសង់ និងរោងចំនួនមួយ។ ក្រោយមកកម្លាំងសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនឈ្មោះ[redacted] ឈិន តែម្តង។

ខ-សាក្សីឈ្មោះ[redacted] សុធារិទ្ធិ បានឆ្លើយបញ្ជាក់ថា: ខ្លួនមានឋានៈជានាយផ្នែកបទឧក្រិដ្ឋព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគីរី។ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ខ្លួន និងកម្លាំងចម្រុះបានចុះបង្ក្រាបបទល្មើសជាក់ស្តែងនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ដោយខ្លួនបានឃើញឈ្មោះ[redacted]ឈិន នៅកន្លែងកើតហេតុ និងឃើញមានការឈូសឆាយពីផ្លូវជាតិប្រវែងប្រហែល ១០គីឡូម៉ែត្រ និងបានឃើញការកាប់រលំដើមឈើធំតូចមួយចំនួន។ ខ្លួនមិនបានដឹងថាអ្នកណាជាអ្នកកាប់រលំដើមឈើនោះទេ។ នៅកន្លែងកើតហេតុ ខ្លួនបានឃើញមានការសាងសង់ផ្ទះចំនួន ០៥ ទៅ០៦, រោងដាក់ម៉ាស៊ីនភ្លើងចំនួនពីរ, និងតាបឈូសឈើ ចំនួនមួយ ព្រមទាំងធ្វើការឃាត់ខ្លួនបានឈ្មោះ[redacted] ឈិន តែម្តង។

គ-សាក្សីឈ្មោះ[redacted] ប៊ុនធឿន បានឆ្លើយបញ្ជាក់ថា: ខ្លួនឡើងកាន់តំណែងជាអនុប្រធានមន្ទីរបរិស្ថាន ទទួលបន្ទុកដែនកំរសីមា និងរបៀងអភិរក្សជីវចម្រុះ ក្នុងឆ្នាំ២០១៩។ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ខ្លួន និងកម្លាំងចម្រុះបានចុះបង្ក្រាបបទល្មើសជាក់ស្តែងនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ដោយខ្លួនបានឃើញមានផ្លូវឈូសឆាយហើយស្រេចបានចំនួនប្រហែលជាង១០គីឡូម៉ែត្រ ដោយមានការប៉ះពាល់ព្រៃឈើ និងមានឃើញដើមឈើធំតូចរលំជាច្រើនដោយគេបានសម្អាតរួចហើយ។ ដីដែលជនជាប់ចោទទាំងអស់ឈូសឆាយនោះ គឺប៉ះពាល់ដល់របៀងអភិរក្សជីវចម្រុះ ដែលភ្ជាប់ពីតំបន់ការពារមួយទៅតំបន់ការពារមួយទៀត ហើយដីទាំងនោះមានទំហំច្បាស់លាស់ និងមានចែងក្នុងអនុក្រឹត្យលេខ ០៧ អនក្របក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីតំបន់របៀងអភិរក្សជីវចម្រុះ។ អនុក្រឹត្យនេះខាងមន្ទីរបរិស្ថានបានដាក់ទៅរដ្ឋបាលខេត្តមណ្ឌលគីរី ធ្វើការផ្សព្វផ្សាយជាបន្តបន្ទាប់ទៀតផង។ ខ្លួនមិនបានឃើញគ្រឿងចក្រនៅកន្លែងកើតហេតុនោះទេ គឺឃើញមានការសាងសង់ផ្ទះចំនួន០៣ កន្លែង ហើយឃើញមានមនុស្សប្រុសម្នាក់ និងស្ត្រីម្នាក់នៅទីតាំងកើតហេតុ។ ចំពោះដីសរុបចំនួន ២៩៨ ហិចតាគឺមិនមានប្រជាជនរស់នៅនោះទេពីព្រោះវាស្ថិតនៅក្នុងដីរបៀងអភិរក្សជីវចម្រុះដែលការអះអាងនេះសំអាងទៅលើនិយាម ការនៅក្នុងផែនទី។ ខ្លួនមិនបានឃើញមានដើមស្វាយចន្ទី តែខ្លួនគ្រាន់តែបានឃើញដើមធូរ៉េនដែលទើបតែបានដាំថ្មីៗប៉ុណ្ណោះ។

ឃ-សាក្សីឈ្មោះ[redacted]ចិន្តា បានឆ្លើយបញ្ជាក់ថា: ខ្លួន គឺជាស្នងការរងទទួលបន្ទុកព្រំដែន។ នាថ្ងៃកើតហេតុខ្លួនមិនបានចុះបង្ក្រាបដោយផ្ទាល់នោះទេ។ ខ្លួនមិនមានភាគហ៊ុនជាមួយឈ្មោះ[redacted] ធី នោះទេ គឺខ្លួនគ្រាន់តែដឹងថាឈ្មោះ[redacted] ធី បានទិញដីមួយចំនួនពីបងប្អូនប៉ូលីសក្នុងឆ្នាំ២០០៦ និងឆ្នាំ២០០៧ នៅចំណុចភ្នំក្បាលខ្មោច ស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី។ ខ្លួនមិនបានប្រើឈ្មោះ[redacted] ម៉េងធី ឲ្យទៅចុះមើលស្ថានភាពព្រំដីនោះទេហើយខ្លួនក៏មិនបានដឹងអំពីការវិនិយោគដីរបស់ឈ្មោះ[redacted] ធី នោះទេ។

ង-សាក្សីឈ្មោះ[redacted] រ៉ាវី បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ខ្លួនបានចូលរួមបង្ក្រាបបទល្មើសជាមួយថ្នាក់ជាតិ នៅកន្លែងកើតហេតុខ្លួនបានឃើញឈ្មោះ[redacted] ឈិន កំពុងអង្គុយនៅកញ្ចុះ និងបានឃើញកូនត្រាក់ទ័រចំនួន ០១, ឡានកៃច្នៃសម្រាប់ដឹកសម្ភារៈចំនួន ០១ និងឃើញមានព្រៃឈើធំតូចរលំមួយចំនួនទៀត។ ខ្លួនបានឃើញមានការឈូសឆាយផ្លូវប្រវែងប្រហែល ១០គីឡូម៉ែត្រ, មានបង្គោលសូឡាប្រហែលជាង ១០ដើម, ផ្ទះចំនួន ០៦ និងបន្ទប់ទឹកធ្វើអំពីឈើចំនួនមួយ។ ចំពោះការឈូសឆាយនោះមានលក្ខណៈធំដុំ។ ចំពោះដីទំហំ ២៩៨ ហិចតា មានសណ្ឋានជាដីភ្នំវាលស្មៅមានព្រៃស្រោង និងស្ថិតក្នុងតំបន់របៀងទាំងស្រុង។ ✓

ច-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ម៉ាប់ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ឆ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ដាន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ជ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] រ៉ាន៊ី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ឈ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] រចនា ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តមណ្ឌលគីរី។

ញ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] សាវឿន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ដ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] គីមសុង ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលខេត្តមណ្ឌលគីរី។

ឋ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ធារ៉ា ហៅគោដេញ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលខេត្តមណ្ឌលគីរី។

ឌ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] សុភាព ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលខេត្តមណ្ឌលគីរី។

ឍ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] កែម ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលខេត្តមណ្ឌលគីរី។

ណ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] សារី ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលខេត្តមណ្ឌលគីរី។

[redacted]

ត-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] រតនា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ថ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ស៊ុនហ៊ន់ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ទ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ស្ទួរ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ធ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ហាន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ខេត្តក្រចេះ។

ន-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] សុន ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ប-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] សុខិត ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ផ-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ណា ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង

ខេត្តក្រចេះ។

ព-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] ឃើន ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ។

ភ-ក្រឡាបញ្ជីអានពាក្យសុំបំភ្លឺសាក្សី ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សេងឃាង។

-ក្រឡាបញ្ជីអានកំណត់ហេតុប្រគល់-ទទួលវត្ថុតាងលេខ៤១/២០ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តមណ្ឌលគិរី, កំណត់ហេតុប្រគល់-ទទួលវត្ថុតាង លេខ:៤២/២០ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តមណ្ឌលគិរី, កំណត់ហេតុប្រគល់-ទទួលវត្ថុតាង លេខ:៤៣/២០ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តមណ្ឌលគិរី, លិខិតប្រគល់-ទទួលជនសង្ស័យ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ, លិខិតប្រគល់ទទួលជនសង្ស័យ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី និងលិខិតប្រគល់-ទទួលជនសង្ស័យ និងសម្ភារ: ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌខេត្តមណ្ឌលគិរី។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ចម្លើយរបស់ជនជាប់ចោទទាំងប្រាំបីនាក់ មានភាពស៊ីសង្វាក់ជាមួយចម្លើយបណ្តាសាក្សី ព្រមទាំងភស្តុតាងនានា បញ្ជាក់ថា: ជនជាប់ចោទទាំងដប់ប្រាំនាក់ពិតជាបានសហការរួមគ្នាក្នុងការកាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈ្លូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិលើដីដែលមានការប៉ះពាល់ដល់ដីរបៀងអភិរក្សជីវចម្រុះ លើទំហំដី ២៩៨ហិចតា ស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

ក-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: នៅក្នុងរឿងនេះពាក់ព័ន្ធនឹងការទិញលក់ដីទំហំ ២៩៨ ហិចតា ស្ថិតនៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី គឺមិនមានការកាប់គាស់ដីព្រៃនោះទេ ដោយសារគ្មានចម្លើយជនជាប់ចោទ និងចម្លើយបណ្តាសាក្សីបញ្ជាក់ថាពីការឈ្លូសឆាយដីនោះទេ ហើយដីទាំងនោះ គឺមានលិខិតបញ្ជាក់ពីការទិញលក់ត្រឹមត្រូវដោយមានការចុះហត្ថលេខាពីភូមិឃុំស្រុក ទើបកូនក្តីរបស់ខ្លួនយល់ថាត្រឹមត្រូវ និងបានទិញ។ ចំពោះការឈ្លូសឆាយផ្លូវ គឺដើម្បីសម្រួលផ្លូវចាស់តែប៉ុណ្ណោះ ដោយកូនក្តីខ្លួនជាម្ចាស់ដី ហើយការចំណាយ គឺឈ្មោះ [redacted] ឈិន ជាអ្នកចេញ។ ចំណែកឯមន្ត្រីសុរិយោដីមិនបានដឹងថា ដីនេះជាដីប៉ះពាល់ដល់ដីបរិស្ថាននោះដែរ។ ចំពោះការផ្សព្វផ្សាយពីដីដែលជាតម្របដីព្រៃប៉ះពាល់ដល់ដីរបៀងអភិរក្សជីវចម្រុះ ដោយផ្អែកតាមអនុក្រឹត្យចុះឆ្នាំ ២០១៧ នោះ គឺមានការយឺតយ៉ាវដោយកូនក្តីខ្លួនបានទិញដីនោះតាំងពីឆ្នាំ ២០០៦ ដល់ឆ្នាំ២០០៧។ ដូច្នេះ មិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ និងមានវិមតិសង្ស័យ និងប្តឹងសុំឱ្យតុលាការធ្វើការពិចារណាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ តាមមាត្រា៣៦១ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

ខ-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ធី គឺមិនបានធ្វើការឈ្លូសឆាយលើដីទំហំ ២៩៨ហិចតា ស្ថិតនៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី នោះទេ។ ដីទាំងនេះកូនក្តីខ្លួនបានទិញពីប្រជាជនដោយមានការទទួលស្គាល់ពីអាជ្ញាធរភូមិឃុំស្រុក។ ដូច្នេះ ប្តឹងសុំឱ្យតុលាការធ្វើការពិចារណាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ តាមមាត្រា៣៦១ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

គ-លោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: នៅក្នុងសំណុំរឿងនេះតំណាងអយ្យការបានចោទប្រកាន់កូនក្តីខ្លួនថាបានកាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈ្លូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ គឺមិនត្រឹមត្រូវនោះទេ ដោយហេតុថា នៅថ្ងៃដែលមានការ

ចុះបង្ក្រាប នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ គឺមិនមានជនណាមួយធ្វើការឈូសឆាយដីនោះទេ ហើយក៏គ្មានវត្តមានកូនក្តីខ្លួនឈ្មោះ [redacted] សុធាវ៉ាន់ នៅទីនោះទេ។ ម្យ៉ាងវិញទៀត ធាតុផ្សំនៃបទល្មើសកាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃ គឺត្រូវតែជាដីព្រៃ ហើយត្រូវបានដឹងថាដីនោះមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែប្រព័ន្ធចុះបញ្ជីដីធ្លីនៅមានកម្រិត ហើយដីដែលឈូសឆាយនេះ គឺជាដីដែលមានការទទួលស្គាល់ពីអាជ្ញាធរភូមិឃុំ ហើយក៏គ្មានភស្តុតាងបញ្ជាក់ថាដីកើតហេតុ គឺជាដីព្រៃនោះទេ។ ប្រសិនបើកូនក្តីខ្លួនបានដឹងថាដីនោះជាដីព្រៃកូនក្តីខ្លួនក៏មិនណែនាំឱ្យឈ្មោះ [redacted] បញ្ញាភា រកដៃគូអភិវឌ្ឍន៍ឡើយ។ ចំពោះដីនោះ គឺឈ្មោះ [redacted] ធី បានទិញប្រជាពលរដ្ឋដោយមានការទទួលស្គាល់ពីពីអាជ្ញាធរ ដែលទាំងនេះបញ្ជាក់ថាឈ្មោះ [redacted] ធី បានកាន់កាប់ដីនោះស្របច្បាប់ ទើបកូនក្តីខ្លួនរកអ្នកអភិវឌ្ឍន៍លើដីស្របច្បាប់នោះ។ ដូច្នេះ ប្តឹងសុំឱ្យតុលាការធ្វើការពិចារណាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទតាមមាត្រា៣៦១ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

ឃ-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានការពារជារួមឱ្យកូនក្តីខ្លួនទាំងអស់តែម្តង។ នៅក្នុងអង្គហេតុដែលនាំឱ្យមានការចោទប្រកាន់នេះ គឺកើតចេញពីការវិនិយោគរបស់ឈ្មោះ [redacted] ធី ដែលដីនោះមានការទទួលស្គាល់ពីអាជ្ញាធរភូមិឃុំ ហើយការចោទប្រកាន់នេះយោងតាមអនុក្រឹត្យលេខ០៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីរបៀងអភិរក្សជីវចំរុះនៃតំបន់ការពារធម្មជាតិ ដែលអនុក្រឹត្យនេះចេញពីការកាន់កាប់ នៅមានចន្លោះប្រហោងមួយចំនួន គឺមានគោលការណ៍លើការណែនាំប្រជាជន។ ប៉ុន្តែតាមចម្លើយសាក្សីជាអនុប្រធានបរិស្ថានបានបញ្ជាក់ថា៖ បើបានអប់រំណែនាំ ហើយមិនរាងចាលនិងត្រូវអនុវត្តទោស។ ម៉្យាងវិញទៀត សូម្បីតែមន្ត្រីសុរិយោដីក៏មិនបានដឹងពីអនុក្រឹត្យនោះដែរ តែបែជាដាក់ទណ្ឌកម្ម ដោយគ្មានការនែនាំ និងគ្មានការអប់រំនោះទេ។ ដូច្នេះ គ្មានភស្តុតាងណាមួយដែលបង្ហាញថាកូនក្តីខ្លួនឈ្មោះ [redacted] ឈិន, ឈ្មោះ [redacted] បញ្ញាភា, ឈ្មោះ [redacted] ធូន និងឈ្មោះ [redacted] ជុង បានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះទេ និងប្តឹងសុំឱ្យតុលាការពិចារណាលើឱ្យរួចផុតពីបទចោទ ព្រមទាំងប្រគល់នូវវត្ថុចាប់យកមកឱ្យកូនក្តីខ្លួនទាំងអស់វិញ។

ង-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: កូនក្តីរបស់ខ្លួនឈ្មោះ ចេង សុខេង មិនមានទំនាក់ទំនងជាមួយជនជាប់ចោទទាំងអស់នោះទេ គឺគាត់គ្រាន់តែជាមន្ត្រីសុរិយោដី ហើយជាអ្នកចុះហត្ថលេខាលើលិខិតស្នាមដែលបញ្ជូនមកពីឈ្មោះ [redacted] វណ្ណារ័ត្ន ដែលបានធ្វើការវាស់វែងតាមការសុំរបស់ឈ្មោះ [redacted] ធី លើទំហំដីដាក់លាក់ដោយចុចជីភីអេសលើដីទំហំ ៦ហិចតាមានបីប្លង់ ដែលដីនោះជាដីវាលមិនមានការពាក់ព័ន្ធជាមួយនឹងដីព្រៃនោះទេ។ ម្យ៉ាងទៀត ការវាស់វែង [redacted] ត្រូវមានលិខិតរណបដែលទទួលស្គាល់ដោយអាជ្ញាធរភូមិឃុំ នៅឆ្នាំ២០០៦ និងឆ្នាំ២០០៧ ហើយការចុះហត្ថលេខារបស់កូនក្តីខ្លួន គឺគ្រាន់តែផ្ទៀងផ្ទាត់រវាងឯកសារចាស់ៗតែប៉ុណ្ណោះ។ ជាងនេះទៅទៀត គំនូសប្លង់ក៏បានបញ្ជាក់យ៉ាងច្បាស់ថា៖ បុគ្គលដែលពាក់ព័ន្ធដីរបស់រដ្ឋត្រូវទទួលខុសត្រូវដោយខ្លួនឯង។ ដូច្នេះ ប្តឹងសុំឱ្យតុលាការធ្វើការពិចារណាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទតាមមាត្រា៣៦១ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

ច-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: កូនក្តីខ្លួនឈ្មោះ [redacted] វណ្ណារ័ត្ន គឺជាមន្ត្រីភូមិបាល ដែលមិនមានទំនាក់ទំនង ឬសកម្មភាពណាមួយលើដីនោះឡើយ គឺគ្រាន់តែគេពឹងឱ្យមន្ត្រីចុះមកវាស់វែងចុចGPS តែប៉ុណ្ណោះ។ ម៉្យាងវិញទៀតម្ចាស់ដីឈ្មោះ [redacted] ធី មានលិខិតកាន់កាន់នៅឆ្នាំ២០០៦ និង ឆ្នាំ២០០៧ ហើយកូនក្តីខ្លួនបានផ្ទៀងផ្ទាត់រួចមកហើយ។ បន្ទាប់ពីវាស់វែងរួច ទើបកូនក្តីខ្លួនបានចុះហត្ថលេខាតាមការវាស់វែងGPS របស់ខ្លួន។ ចំពោះការចុះហត្ថលេខាលើដីចំនួន ០៦ ហិចតា ដែលចែកជាបីប្លង់ គឺជាដីវាលមិនមែនជាដីព្រៃ គឺម្ចាស់ដីគ្រាន់តែចង់ផ្ទៀងផ្ទាត់ទំហំដី និងមានចែងក្នុងសម្គាល់ប្លង់ខ្ចីម៉ាស់យ៉ាងច្បាស់លាស់ ថាសាមីខ្លួនជាម្ចាស់ដីជាអ្នកទទួលខុសត្រូវ នាខណៈពេលចុះបង្ក្រាបក៏មិនមានវត្តមានរបស់កូនក្តីខ្លួននៅទីនោះដែរ។ ដូច្នេះ ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដាក់បន្ទុកលើកូនក្តីរបស់ខ្លួននោះទេ និងប្តឹងសុំឱ្យតុលាការពិចារណាលើការឱ្យរួចផុតពីបទចោទ។

ឆ-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: អង្គហេតុទាំងអស់ គឺកើតចេញពីការវិនិយោគស្រប ច្បាប់ ពីព្រោះមានការដឹងឮពីអាជ្ញាធរភូមិឃុំ ដោយហេតុថា៖ ឈ្មោះ [redacted] ធី ជាម្ចាស់ដីបានរកដៃគូវិនិយោគឈ្មោះ [redacted] ឈិន ដើម្បីអភិវឌ្ឍន៍លើដីនោះ ដោយដីនោះមានលិខិតស្នាមត្រឹមត្រូវដោយបានទទួលស្គាល់ពីអាជ្ញាធរភូមិឃុំស្រុក។ ម្យ៉ាងទៀត កូនក្តីឈ្មោះ [redacted] ឈិន មិនមានចេតនាប្រព្រឹត្តល្មើសឈូសឆាយដីព្រៃនោះទេ គឺតាមកិច្ចសន្យារវាងឈ្មោះ [redacted] ធី និងកូនក្តីឈ្មោះ [redacted] ឈិន បានថែងថា:ឈ្មោះ [redacted] ធី ជាអ្នកធានាថាដីនោះជាដីរបស់ខ្លួន និងមានកាតព្វកិច្ចរត់ការលើដីនោះទាំងស្រុង។ ដូច្នេះ គ្មានភស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted] ឈិន នោះទេ។ ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] ម៉េងធី គ្រាន់តែអ្នកសារព័ត៌មាន ដោយមិនមានពាក់ព័ន្ធទៅនឹងការឈូសឆាយដីព្រៃនោះទេ។ ដូច្នេះក៏គ្មានភស្តុតាងដាក់បន្ទុកលើកូនក្តីខ្លួនឈ្មោះ [redacted] ម៉េងធី នោះដែរ។ រីឯកូនក្តីខ្លួនឈ្មោះ [redacted] ម៉ាប់, ឈ្មោះ [redacted] សាន, ឈ្មោះ [redacted] សុភក្តិ, ឈ្មោះ [redacted] វន, ឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] សំណាង គឺជនទាំងអស់នេះមិនមានវត្តមាននៅទីកន្លែងកើតហេតុទេ ហើយក៏មិនមែនមានន័យថា: ពួកគាត់បានប្រព្រឹត្តបទល្មើសឈូសឆាយដីព្រៃនោះដែរ។ ដូច្នេះគ្មានភស្តុតាងដាក់បន្ទុកលើកូនក្តីខ្លួនទាំងប្រាំបីនាក់នោះទេ។ ដូច្នេះប្តឹងសុំឱ្យតុលាការពិចារណា និងសម្រេចឱ្យកូនក្តីខ្លួនទាំងអស់បានរួចផុតពីបទចោទ។

១-ជនជាប់ចោទឈ្មោះ [redacted] ធី និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ ។

២-ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ាន់ និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

៣-ជនជាប់ចោទឈ្មោះ [redacted] ឈិន និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

៤-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាភា និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

៥-ជនជាប់ចោទឈ្មោះ [redacted] ធួន និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

៦-ជនជាប់ចោទឈ្មោះ [redacted] មេងធី និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

៧-ជនជាប់ចោទឈ្មោះ [redacted] សុខខេង និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

៨-ជនជាប់ចោទឈ្មោះ [redacted] ដុង និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការសម្រេចដោះលែងឱ្យខ្លួន។

-ក្រោយពីបានស្តាប់-ការអានចម្លើយបណ្តាជនជាប់ចោទ។

-ក្រោយពីបានស្តាប់-ការអានចម្លើយបណ្តាសាក្សី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយជនជាប់ចោទ។

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា។

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាគ្នាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តក្រចេះ

## យល់ឃើញថា

១-ដីកាដំណោះស្រាយលេខ:៦៥៦៣.ស/២១ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ បានសម្រេចបញ្ជូនឈ្មោះ [redacted] ធី ហៅចិត្រ ភេទប្រុស អាយុ ៥៥ឆ្នាំ, ឈ្មោះ [redacted] សុធារ៉ាន់ ភេទប្រុស អាយុ ៤៣ឆ្នាំ, ឈ្មោះ [redacted] ឈិន ភេទប្រុស អាយុ ៣៦ឆ្នាំ, ឈ្មោះ [redacted] បញ្ញាភា ភេទប្រុស អាយុ ៣៩ឆ្នាំ, ឈ្មោះ [redacted] ធួន ភេទប្រុស អាយុ ៣០ឆ្នាំ, ឈ្មោះ [redacted] ម៉េងធី ភេទប្រុស អាយុ ៤៧ឆ្នាំ, ឈ្មោះ [redacted] ដុង ភេទប្រុស អាយុ ៥១ឆ្នាំ, ឈ្មោះ [redacted] សុភក្តិ ភេទប្រុស អាយុ ៤៥ឆ្នាំ, ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៤៨ឆ្នាំ, ឈ្មោះ [redacted] វណ្ណារ័ត្ន ភេទប្រុស អាយុ ៣៣ឆ្នាំ, ឈ្មោះ [redacted] សុខេង ភេទប្រុស អាយុ ៤៤ឆ្នាំ, ឈ្មោះ [redacted] ម៉ាប់ ហៅម៉ាប់ប៊ូស្រា ភេទប្រុស អាយុ ៤២ឆ្នាំ, ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅណាងទាប៊ាន



Scanned with CamScanner

ភេទប្រុស អាយុ ៤៧ឆ្នាំ, ឈ្មោះ[redacted]វន ហៅសុវណ្ណឌី ភេទប្រុស អាយុ ៦០ឆ្នាំ និងឈ្មោះ[redacted] សាន ភេទប្រុស ពីបទ: កាប់គាស់ រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា ៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

២-ជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ បានឆ្លើយដោះសារនាពេលសវនាការថា: ខ្លួនបានឱ្យឈ្មោះ[redacted]សុធារ៉ាន់ ណែនាំឈ្មោះ[redacted] ឈិន ឱ្យខ្លួនស្គាល់ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍ដោយសន្យាឱ្យប្រាក់កម្រៃជើងសារទៅឈ្មោះ[redacted] សុធារ៉ាន់។ ដីដែលខ្លួនចង់អភិវឌ្ឍន៍នោះ គឺជាដីដែលខ្លួនទិញពីប្រជាពលរដ្ឋចំនួន ៧នាក់មានទំហំដីសរុបចំនួន ២៩៨ ហិចតា នៅចំណុចភ្នំក្បាលខ្មោច ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ក្នុងឆ្នាំ២០០៦ និងឆ្នាំ២០០៧ ដោយមានចុះហត្ថលេខាមេភូមិ គឺលោក[redacted]ឈិន និងមេឃុំ គឺលោក[redacted] វ៉ាន់នី និងអភិបាលស្រុកលោក[redacted] ស៊ុន ដោយដីនេះមានការវាស់វែងកំណត់ព្រំដីដោយមានប្លង់ឌីម៉ាស់វាស់វែងដោយGPS ត្រឹមត្រូវ ចេញដោយមន្ត្រីវាស់វែង និងមានការចុះហត្ថលេខាដោយប្រធានភូមិបាលស្រុកអូររាំង តែមិនមានការទទួលស្គាល់ពីសុរិយោដី ហើយដីនោះមិនមានការពាក់ព័ន្ធជាមួយជម្រកព្រៃឈើតំបន់ធម្មជាតិ ដោយដីទាំងនោះមានដាំដំណាំធូរ៉េន ចំនួន ២០ហិចតា និងដាំដំណាំផ្សេងៗលើផ្ទៃដីចំនួន ៣ហិចតា។ ក្រោយមកនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ ខ្លួនបានចុះកិច្ចព្រមព្រៀងគ្នាជាមួយឈ្មោះ[redacted] ឈិន តាមការណែនាំរបស់ឈ្មោះ[redacted] សុធារ៉ាន់ លើការវិនិយោគដីទំហំ ២៨៩ ហិចតា ខាងលើ។ ចំពោះកិច្ចសន្យាវិនិយោគដីនេះ គឺមានភាគីម្ចាស់ដីតែខ្លួនម្នាក់គត់ ចំណែកឯភាគីខាងវិនិយោគរួមមានឈ្មោះ[redacted] ឈិន, ឈ្មោះ[redacted] ធូន, ឈ្មោះ[redacted] បញ្ញាភា និងឈ្មោះ[redacted] សុធារ៉ាន់ ដោយក្នុងកិច្ចព្រមព្រៀងនោះខ្លួនមានភាគហ៊ុន ចំនួន៦០% ជាភាគីម្ចាស់ដី និងភាគីវិនិយោគមានភាគហ៊ុនចំនួន ៤០%។ ចំណែកឯរឿងវិនិយោគនោះខ្លួនមិនដឹងថាពួកគេបានលុយមកពីណានោះទេ។ បន្ទាប់ពីចុះកិច្ចសន្យារួចមក ខ្លួនមានភាគីកិច្ចជាអ្នកទទួលខុសត្រូវលើដីរាល់ការពាក់ព័ន្ធជាមួយគម្របព្រៃឈើតំបន់ធម្មជាតិ ឬពាក់ព័ន្ធជាមួយកម្មសិទ្ធិរបស់អ្នកណាម្នាក់ និងមានភាគីកិច្ចយកគ្រឿងចក្រយកមកធ្វើការឈូសឆាយផ្លូវ។ ចំពោះការឈូសឆាយផ្លូវនេះ ខ្លួនបានទៅសុំអាជ្ញាធរឃុំដោយផ្ទាល់មាត់។ រីឯគ្រឿងចក្រត្រាក់ទ័រ គឺឈ្មោះ[redacted] ម៉ាប់ ជាអ្នកជួល និងមើលការខុសត្រូវ។ រីឯក្រុមវិនិយោគីបានសាងសង់ផ្ទះមួយ និងតូបកាហ្វេមួយដែលការសាងសង់នោះ គឺសាងសង់លើកំពូលភ្នំ និងមិនបានឈូសដើមឈើអ្វីនោះទេ។ លុះនៅថ្ងៃខែមិនចាំ[redacted] ឈ្មោះ[redacted] ម៉េងធី បានប្រាប់មកខ្លួនថា: លោកអភិបាលស្រុកមិនឱ្យឈូសឆាយដីនោះទេពីព្រោះដីនេះប៉ះពាល់ជាមួយគម្របដីព្រៃឈើ។ តាមចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ គឺគ្មានភស្តុតាងណាមួយដែលអាចដោះបន្ទុកឱ្យខ្លួនបានឡើយពីព្រោះថា ដីដែលជនជាប់ចោទបានអះអាងបានទិញពីប្រជាជននោះ គឺជាដីមិនទាន់បានចុះបញ្ជីបញ្ជាក់ពីកម្មសិទ្ធិរបស់ខ្លួននៅឡើយហើយការធ្វើការអភិវឌ្ឍន៍ជាមួយជនជាប់ចោទដទៃទៀតលើដីមានទំហំ ២៩៨ហិចតា នៅចំណុចភ្នំរហាំង ស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរីក៏មិនបានចុះបញ្ជី និងមានការអនុញ្ញាតឱ្យមានការវិនិយោគលើដីនោះដែរ ។ម្យ៉ាងវិញទៀត ការឈូសឆាយលើដីមានទំហំ ២៩៨ហិចតា ដើម្បីធ្វើការអភិវឌ្ឍន៍នោះ គឺគ្មានលិខិតណាអនុញ្ញាតឱ្យជនជាប់ចោទឈ្មោះ[redacted]ធី ធ្វើការឈូសឆាយនោះទេទោះបីជាជនជាប់ចោទឈ្មោះ[redacted]ធី បានព្រមព្រៀងគ្នាដោយខ្លួនជាអ្នកធានាកាតព្វកិច្ចខ្លួនដូចមានក្នុងកិច្ចសន្យាព្រមព្រៀងវិនិយោគអចលនទ្រព្យ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ រវាងឈ្មោះ[redacted] ធី ហៅចិត្រ និងឈ្មោះ[redacted]ឈិន ក៏ដោយ។ ម៉្យាងទៀត ការឆ្លើយបញ្ជាក់នាពេលសវនាការរបស់ជនជាប់ចោទឈ្មោះ[redacted] ធី ហៅចិត្រ បានបញ្ជាក់ថា: ខ្លួនជាភាគីទទួលខុសត្រូវលើដីអភិវឌ្ឍន៍នោះ និងជាអ្នករត់ការលើដីនោះក៏មិនមែនមានន័យថាដីនោះពិតជាកម្មសិទ្ធិរបស់ជនជាប់ចោទឈ្មោះ[redacted]ធី ហៅចិត្រ នោះទេ។ ផ្ទុយទៅវិញ យោងតាមអនុក្រឹត្យលេខ ០៧អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវចម្រុះប្រពន្ធ័តំបន់ការពារធម្មជាតិ និងការទៅនិយាយប្រាប់របស់

ជនជាប់ចោទឈ្មោះ [redacted] ម៉េងធី បានថា: លោកអភិបាលស្រុកឱ្យបញ្ឈប់ការឈូសឆាយជាបន្ទាន់តែជនជាប់ចោទឈ្មោះ [redacted] ធី នៅតែបន្តសកម្មភាពឈូសឆាយដោយមិនខ្លាចញញើតនូវការបំពានឡើយ។ ចំណែកចម្លើយរបស់ជនជាប់ចោទឈ្មោះអ៊ី សុភក្តិ បានឆ្លើយបញ្ជាក់ថា: ក្នុងឆ្នាំ២០២០ ខ្លួនបានទៅលេងដីរបស់ជនជាប់ចោទឈ្មោះ [redacted] ធី និងបានដឹងច្បាស់ថា ដីរបស់ឈ្មោះ [redacted] ធី ជាដីស្ថិតនៅក្នុងច្រករបៀងរបស់ក្រសួងបរិស្ថាន ខ្លួនដឹងដោយសារខ្លួនបានផែកមើលផែនទី ហើយខ្លួនបានប្រាប់ទៅជនជាប់ចោទឈ្មោះ [redacted] ធី ថាដីនេះដីស្ថិតនៅក្នុងច្រករបៀងរបស់ក្រសួងបរិស្ថាន។ រីឯចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជុង បានឆ្លើយបញ្ជាក់នៅសមត្ថកិច្ចបញ្ជាក់ថា: ក្នុងឆ្នាំ២០២០ ឈ្មោះ [redacted] ធី បានឱ្យឈ្មោះ [redacted] វន យកគ្រឿងចក្រទៅឈូសឆាយនៅតំបន់នោះបណ្តាលឱ្យមានការប៉ះពាល់ព្រៃឈើដោយមានការឈូសឆាយផ្សេងទៀតមានប្រហែលចំនួន ១០ហិចតា ហើយការឈូសឆាយលើដីនោះ គឺគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដើម្បីអនុញ្ញាតឱ្យជនជាប់ចោទឈូសឆាយនៅលើដីនោះទេ។ ម្យ៉ាងវិញទៀតនៅពេលចុះបង្ក្រាបបទល្មើសឃើញថាពិតជាមានការឈូសឆាយដីប្រមាណជាង ១០គីឡូម៉ែត្រ ធ្វើឱ្យមានការប៉ះពាល់ព្រៃឈើ និងដើមឈើតូចធំជាច្រើន ព្រមទាំងបានធ្វើការសាងសង់ផ្ទះ រោងដាក់ម៉ាស៊ីនភ្លើង ផងដែរ ។ ទាំងអស់នេះបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] ធី ហៅចិត្រ ពិតជាមានចេតនាធ្វើការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ទោះបីដឹងថា: ដីដែលខ្លួនកំពុងកាន់កាប់នោះមានការប៉ះពាល់ជាមួយគម្របដីព្រៃឈើ នៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ នោះក៏ដោយ។

៣-ជនជាប់ចោទឈ្មោះ [redacted] ឈិន បានឆ្លើយដោះសារនាពេលសវនាការថា: ខ្លួនមិនបានដឹងថាដីទំហំ២៩៨ ហិចតានោះមានការពាក់ព័ន្ធជាមួយដីបរិស្ថាន និងគម្របព្រៃឈើនោះទេ។ លើសពីនេះទៅទៀតប្រសិនបើខ្លួនដឹងថាដីនេះមានបញ្ហានោះ ខ្លួនក៏មិនចុះកិច្ចសន្យាអភិវឌ្ឍន៍ជាមួយឈ្មោះ [redacted] ធី នោះដែរដោយមានការទុកចិត្តគ្នាជាមួយឈ្មោះ [redacted] ធី ទើបឈានដល់មានការចុះកិច្ចសន្យារវាងម្ចាស់ដីឈ្មោះ [redacted] ធី និងខ្លួនគឺជាអ្នកអភិវឌ្ឍន៍ ដោយមានឈ្មោះ [redacted] បញ្ញាភា, ឈ្មោះ [redacted] ធូន និងឈ្មោះ [redacted] សុធារ៉ាន់ ធ្វើជាសាក្សីក្នុងកិច្ចសន្យានោះ ព្រមទាំងបានបង្កើតលក្ខន្តិកៈក្រុមហ៊ុនដាក់ដាំអិនវេសមែនដោយមានឈ្មោះ [redacted] ធី ជាប្រធានក្រុមប្រឹក្សាភិបាល, ខ្លួនជាអគ្គនាយក, ឈ្មោះ [redacted] សុធារ៉ាន់, ឈ្មោះ [redacted] ធូន និងឈ្មោះ [redacted] បញ្ញាភា ជាសមាជិក ដោយលក្ខន្តិកៈក្រុមហ៊ុនមិនមានចុះបញ្ជីត្រឹមត្រូវនោះទេ។ ចំពោះឈ្មោះ [redacted] សុធារ៉ាន់ យកកម្រៃជើងសារពីម្ចាស់ដីឈ្មោះ [redacted] ធី ចំណែកឯឈ្មោះ [redacted] បញ្ញាភា និងឈ្មោះ [redacted] ធូន យកកម្រៃជើងសារពីខ្លួនចំនួន ១៣% ក្នុងម្នាក់ៗ។ ខ្លួនសូមបញ្ជាក់ថា:អ្នកដែលទទួលបានកម្រៃជើងសារទាំងបីនាក់ គឺមិនមានភាគហ៊ុននៅក្នុងកិច្ចសន្យានោះឡើយ។ បន្ទាប់មកនៅអំឡុងឆ្នាំ២០២០ ខ្លួនបានលក់ដីក្នុងគម្រោងនេះចំនួន ០៦ហិចតា ដែលដីទាំងនេះមានសណ្ឋានជាដីវាលស្មៅធម្មតាទៅឱ្យអតិថិជន ០៣រូប និងមានឯកសារទិញលក់បានចុះហត្ថលេខាត្រឹមភូមិឃុំ និងមិនទាន់មានចុះហត្ថលេខាដល់ស្រុកនៅឡើយទេ។ តាមចម្លើយដោះសារជនជាប់ចោទឈ្មោះ [redacted] ឈិន គឺគ្មានភស្តុតាងណាមួយដែលអាចដោះបន្ទុកឱ្យខ្លួនបានឡើយ ដោយហេតុថា: ជនជាប់ចោទឈ្មោះ [redacted] ឈិន មិនត្រូវបានគេបោកបញ្ឆោត ឬលួងលោម ឱ្យចូលរួមវិនិយោគនោះទេមានន័យថា: រាល់ការចុះកិច្ចសន្យារវាងជនជាប់ចោទឈ្មោះ [redacted] ធី និងជនជាប់ចោទឈ្មោះ [redacted] ឈិន គឺជាការព្រមព្រៀងគ្នាដោយគ្មានការបង្ខិតបង្ខំដោយជនជាប់ចោទឈ្មោះ [redacted] ឈិន បានស្ម័គ្រចិត្តធ្វើការវិនិយោគជាមួយជនជាប់ចោទឈ្មោះ [redacted] ធី ដោយខ្លួនឯងដែលជាកត្តាបង្ហាញឱ្យឃើញយ៉ាងច្បាស់ថាជនជាប់ចោទឈ្មោះ [redacted] ឈិន ប្រាកដជាដឹងអំពីស្ថានភាពដីដែលខ្លួនវិនិយោគនោះជាពុំខានដូចជាការចំណាយប្រាក់ដើម្បីរៀបចំទីកន្លែង ការដាក់សូឡា ធ្វើផ្ទះ និងបន្ទប់ទឹក ដែលជនជាប់ចោទឈ្មោះ [redacted] ឈិន មានគោលបំណងយ៉ាងច្បាស់ក្នុងការយកដីរដ្ឋដើម្បីធ្វើការចាត់ចែងតាមចិត្តរបស់ខ្លួន។ ម្យ៉ាងទៀត ប្រសិនជនជាប់ចោទឈ្មោះ [redacted] ឈិន ជាអ្នកវិនិយោគសុចរិតត្រឹមត្រូវហើយមានបំណងអភិវឌ្ឍន៍លើដីទំហំ ២៩៨ ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី គឺជនជាប់ចោទឈ្មោះ [redacted] ឈិន ត្រូវធ្វើការសិក្សាស្រាវជ្រាវ និងរកអ្នកជំនាញដើម្បីឱ្យដឹង

ថា: តើដីនោះអាចមានបញ្ហាអ្វីខ្លះនឹងត្រូវកើតឡើងនាខណៈពេលដែលខ្លួនអភិវឌ្ឍន៍លើដីនោះហើយជនជាប់ចោទឈ្មោះ[redacted] ឈិន ក៏មិនអាចឆ្លើយដោះសារថា: ខ្លួនជឿជាក់លើលិខិតស្នាមដីធ្លីដែលមានការចុះហត្ថលេខាថ្នាក់ភូមិឃុំស្រុក និងកិច្ចព្រមព្រៀងវិនិយោគអចលនទ្រព្យ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ រវាងឈ្មោះ[redacted] ធី និងឈ្មោះសាន ឈិន និងការធានារបស់ជនជាប់ចោទឈ្មោះ[redacted] ធី ពីព្រោះលិខិតស្នាមដីធ្លីរបស់ជនជាប់ចោទឈ្មោះ[redacted] ធី គឺជាដីមិនទាន់ចុះបញ្ជីជាដីកម្មសិទ្ធិរបស់ជនជាប់ចោទឈ្មោះ[redacted] ធី នោះទេហើយការធានាអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted] ធី ក៏មិនមែនជាលិខិតចេញពីអាជ្ញាធរច្បាប់ធានាថាដីដែលចង់អភិវឌ្ឍន៍នោះ គឺមិនមានការប៉ះពាល់ដល់ដីបរិស្ថាន ឬគម្របព្រៃឈើ ឬដីរបស់រដ្ឋនោះទេ។ ម្យ៉ាងទៀតដីដែលជនជាប់ចោទឈ្មោះ[redacted] ឈិន ធ្វើការវិនិយោគជាមួយជនជាប់ចោទឈ្មោះចាន់ ធី គឺដីមានទំហំដីធំ និងស្ថិតនៅតំបន់ជាយដាច់ឆ្ងាយក្នុងព្រៃដោយតម្រូវឱ្យជនជាប់ចោទឈ្មោះ[redacted] ឈិន ធ្វើការពិចារណា និងសិក្សាស្រាវជ្រាវឱ្យបានច្បាស់លាស់ជាមុន។ ផ្ទុយទៅវិញជនជាប់ចោទឈ្មោះ[redacted] ឈិន បែរជាចូលរួម និងជម្រុញយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍លើដីនោះដោយឈូសឆាយព្រៃបង្កើតជាវីស៊ីតដាក់បង្គោល សឡា១០ដើម ផ្ទះចំនួន៦ និងបន្ទប់ទឹក និងពុះដីឡូត៍លក់បានចំនួនបីប្លង់(៦ហិចតា) ព្រមទាំងឈូសឆាយផ្លូវប្រហែល១០គីឡូម៉ែត្រទៀតផង ហើយជនជាប់ចោទឈ្មោះ[redacted] ឈិន ក៏ត្រូវបានឃាត់ខ្លួននាខណៈពេលកម្លាំងចម្រុះថ្នាក់ជាតិចុះបង្ក្រាបផងដែរ។ ដូច្នេះតាមចម្លើយសាក្សីឈ្មោះ[redacted] រ៉ាវី និងបណ្តាសាក្សីមានភាពស៊ីសង្វាក់ជាមួយ ភស្តុតាងនានាបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] ឈិន ពិតជាមានចេតនាចូលរួមធ្វើការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរបាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ប្រាកដមែន។

៤-ជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា បានឆ្លើយនាពេលសវនាការបញ្ជាក់ថា: ខ្លួនស្គាល់ឈ្មោះ[redacted] ធី តាមរយៈឈ្មោះ[redacted] សុធារ៉ាន់ ហើយឈ្មោះ[redacted] សុធារ៉ាន់ បានប្រាប់មកខ្លួនថាឈ្មោះ[redacted] ធី មានដីទំហំ ២៩៨ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដែលជាដីស្របច្បាប់របស់ឈ្មោះ[redacted] ធី។ បន្ទាប់មកខ្លួនបានចុះទៅមើលដីនោះនិងឃើញឈ្មោះ[redacted] ធី មានប្លង់ឌីម៉ាស់ និងឯកសារផ្សេងៗដែលគាត់បានទិញដីនោះក្នុងអំឡុងឆ្នាំ២០០៦ និងឆ្នាំ២០០៧ ហើយដីនោះមិនមានការពាក់ព័ន្ធជាមួយដីរបស់រដ្ឋដោយឈ្មោះ [redacted] ធី បង្ហាញពីលិខិតស្នាមត្រឹមត្រូវបញ្ជាក់ថាដីទាំងនោះជាដីស្របច្បាប់ ទើបខ្លួនបាននាំទៅឈ្មោះ[redacted] ឈិន។ នៅថ្ងៃទីមិនចាំខែមេសា ឆ្នាំ២០២០ ឈ្មោះចាន់ ធី និងឈ្មោះ[redacted] ឈិន បានចុះកិច្ចសន្យាព្រមព្រៀង ដោយឈ្មោះ[redacted] ធី ជាភាគីម្ចាស់ដី និងឈ្មោះ[redacted] ឈិន ជាភាគីម្ខាងទៀត។ រីឯខ្លួន និងឈ្មោះ[redacted] សុធារ៉ាន់ គ្រាន់តែ[redacted] ជាសាក្សីដោយខ្លួនជាសាក្សីឱ្យឈ្មោះ[redacted] ឈិន ហើយឈ្មោះ[redacted] សុធារ៉ាន់ ជាសាក្សីឱ្យឈ្មោះចាន់ ធី។ បន្ទាប់មក[redacted]បានបង្កើតលក្ខនិកៈក្រុមហ៊ុនហ្វូណេសាន ដោយលក្ខន្តិកៈក្រុមហ៊ុនមិនទាន់បានចុះបញ្ជី ក្នុងនោះមានឈ្មោះ[redacted] ធី ជាប្រធានក្រុមប្រឹក្សាភិបាល និងមានឈ្មោះ[redacted] ឈិន ជាអគ្គនាយក ហើយឈ្មោះ[redacted] សុធារ៉ាន់, ឈ្មោះ[redacted] ធូន និងឈ្មោះ[redacted] បញ្ញាភា គឺជាសមាជិក។ មូលហេតុដែលខ្លួនជាសមាជិកនៅក្នុងលក្ខន្តិកៈក្រុមហ៊ុននោះ គឺការពារក្នុងការទទួលបានកម្រៃជើងសារ ១៣% លើការនែនាំរវាងឈ្មោះ[redacted] ធី និងឈ្មោះសាន ឈិន ដោយខ្លួនយកពីឈ្មោះ[redacted] ឈិន តែមិនទាន់បានទទួលកម្រៃជើងសារនៅឡើយទេ។ នៅពេលនោះ មានការចេញចូលនៅតំបន់ដីនោះ គឺគ្មានអាជ្ញាធរណាម្នាក់មកហាមឃាត់នោះទេ។ បន្ទាប់មកខ្លួនបានជួយលក់បានដីមានអ្នកទិញបីម្ចាស់នូវដីចំនួន០៦ហិចតា លើផ្ទៃដីវាលដែលមិនមានព្រៃនោះក្នុងតម្លៃ៣ម៉ឺនដុល្លារអាមេរិកក្នុងមួយហិចតាដោយទទួលប្រាក់កក់ចំនួន ១០% ដោយខ្លួនបានប្រគល់ប្រាក់នោះឱ្យទៅឈ្មោះ[redacted] ឈិន។ ផ្ទុយទៅវិញជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា បែរជាមានឈ្មោះជាសាក្សីក្នុងកិច្ចព្រមព្រៀងវិនិយោគអចលនទ្រព្យ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ រវាងឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ឈិន ហើយមានឈ្មោះជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា និងជនជាប់ចោទឈ្មោះ[redacted] ធូន ជាសមាជិកក្នុងក្រុមហ៊ុន (មិនទាន់ចុះបញ្ជី) ទៀតផង។ ម្យ៉ាងទៀត ជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា បានជួយលក់ដីបានចំនួន ៦

ហិចតាលើដីនោះហើយជនជាប់ចោទឈ្មោះ [redacted] ធូន ក៏បានចូលរួមជួយលក់ដីផងដែរទៀតផង។ មិនតែប៉ុណ្ណោះជនជាប់ចោទឈ្មោះ[redacted]បញ្ញាភា បានឆ្លើយបញ្ជាក់ទទួលស្គាល់ថា:ជនជាប់ចោទឈ្មោះ [redacted] ធី ជាអ្នកទទួលខុសត្រូវឈូសឆាយសម្រួលផ្លូវដី និងបានផ្តិតមេដៃជាសាក្សីនៅក្នុងកិច្ចព្រមព្រៀងវិនិយោគអចលនវត្ថុរវាងឈ្មោ[redacted] ឈិន និងឈ្មោ[redacted] ធី ដោយកិច្ចព្រមព្រៀងនោះបានចែងច្បាស់លាស់ពីគម្រោងអភិវឌ្ឍន៍ ក៏ដូចជាការឈូសឆាយដីដែលចំណុចនេះបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា ពិតជាបានដឹងពីចេតនារបស់ជនជាប់ចោទឈ្មោះ[redacted] ធី និងជនជាប់ចោទឈ្មោ[redacted] ឈិន ក្នុងការយកដីគម្របព្រៃឈើមកអភិវឌ្ឍន៍មកធ្វើដីរបស់ខ្លួន។ រីឯ ជនជាប់ចោទឈ្មោះ[redacted] ធូន បានឆ្លើយនាពេលសវនាការបញ្ជាក់ថា: ឈ្មោះ[redacted] ឈិន និងឈ្មោះ[redacted] បញ្ញាភា បានហៅខ្លួនចូលរួមក្នុងការវិនិយោគនៅលើដីទំហំ ២៩៨ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ដោយខ្លួនបានដាក់ឈ្មោះធ្វើជាសមាជិកក្នុងលក្ខនិកៈក្រុមហ៊ុន(មិនទាន់ចុះបញ្ជី) ក្នុងគោលបំណងដើម្បីទទួលបានកម្រៃជើងសារចំនួន ១៣% ពីឈ្មោះ[redacted] ឈិន ។ ខ្លួនមិនបានដឹងថា ដីនោះជារបស់អ្នកណាទេ និងមានការពាក់ពន្ធ័ជាមួយដីរដ្ឋ ឬយ៉ាងណា គឺខ្លួនមិនដឹងទេហើយខ្លួនក៏មិនបានធ្វើជាសាក្សីក្នុងកិច្ចសន្យានោះដែរ។ ខ្លួនធ្លាប់ទៅទីតាំងដីនោះបានចំនួនបីដង ហើយខ្លួនមានតួនាទីជាអ្នកទីផ្សារនៅក្នុងគម្រោងលក់ដីនោះ តែខ្លួនមិនទាន់បានលក់ដីបានមួយប្លង់ទេ។ ចំពោះការលក់ដីបីប្លង់នោះ គឺឈ្មោះ[redacted]ឈិន និងឈ្មោ[redacted] បញ្ញាភា ជាអ្នកលក់ ហើយខ្លួនក៏មិនទាន់ទទួលបានកម្រៃជើងសារទេ ពីព្រោះខ្លួនមិនទាន់រកម៉ូយលក់ដីនោះបាននៅឡើយ។ ខ្លួនមិនបានដឹងអំពីការឈូសឆាយដីព្រៃនោះទេ។ តាមចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា និងជនជាប់ចោទឈ្មោះ[redacted] ធូន គឺគ្មានភស្តុតាងណាមួយដែលអាចដោះបន្ទុកឱ្យខ្លួនបានឡើយ ដោយហេតុថា: តាមចម្លើយជនជាប់ចោទ និងបណ្តាសាក្សីព្រមទាំងភស្តុតាងណានានាបញ្ជាក់ថា: ដីទំហំ ២៩៨ ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី គឺជាដីមិនបានចុះបញ្ជីត្រឹមត្រូវ និងក្លាយជាកម្មសិទ្ធិស្របច្បាប់របស់ជនជាប់ចោទឈ្មោះ[redacted] ធី នៅឡើយទេ ហើយការអភិវឌ្ឍន៍លើដីនោះក៏គ្មានការអនុញ្ញាតពីស្ថាប័នសមត្ថកិច្ចណាមួយនៅឡើយដែរ។ ម្យ៉ាងទៀត ជនជាប់ចោទឈ្មោះ[redacted] ធូន បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថា: ខ្លួនជាបុគ្គលិកផ្នែកអចលនទ្រព្យ។ ដូច្នេះ ជនជាប់ចោទឈ្មោះ[redacted] ធូន មានការយល់ដឹងយ៉ាងច្បាស់ថាដីនេះអាចនឹងមានការប៉ះពាល់ដីរបស់រដ្ឋ ឬដីបរិស្ថានយ៉ាងណា និងត្រូវដឹងទៀតថា: តើដីនោះត្រូវមានការចុះបញ្ជីត្រឹមត្រូវ និងមានការអនុញ្ញាតឱ្យមានការអភិវឌ្ឍន៍លើតំបន់ដីនោះឬទេ? ប្រសិនបើជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា និងជនជាប់ចោទឈ្មោះ[redacted] ធូន មានការបារម្ភខ្លាចមានការបាត់បង់កម្រៃជើងសារ គឺជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា និងជនជាប់ចោទឈ្មោះ[redacted] ធូន អាចធ្វើជាកិច្ចសន្យាកម្រៃជើងសារជាមួយជនជាប់ចោទឈ្មោះ[redacted] ឈិន ដាច់ដោយឡែកមួយផ្សេងទៀត។ ផ្ទុយទៅវិញជនជាប់ចោទឈ្មោះ[redacted] ធូន មានមុខរបរជាបុគ្គលិកផ្នែកអចលនវត្ថុដោយមានជំនាញក្នុងវិស័យអចលនវត្ថុក្នុងការទិញលក់អចលវត្ថុក៏ដូចជាឯកសារតាមផ្លូវច្បាប់ផ្សេងៗ និងពិតជាបានដឹងយ៉ាងច្បាប់ថា ដីប្រភេទណាដែលជាដីស្របច្បាប់ឯកជនហើយដីប្រភេទណាជាដីរដ្ឋ។ ដូច្នេះ គ្មានហេតុផលណាមួយដែលជនជាប់ចោទឈ្មោះ[redacted] ធូន ផ្តិតម្រាមដៃជាសមាជិកក្រុមហ៊ុនទាំងមិនទាន់បានស្គាល់ច្បាប់ពីប្រវត្តិដីនោះទេ ហើយជនជាប់ចោទឈ្មោះ[redacted] ធូន ពិតជាបានដឹងថា ដីដែលមានសណ្ឋានជាដីព្រៃជុំវិញ ដីភ្នំមានវាលស្មៅ និងព្រៃស្បោង អាចជាដីមានការប៉ះពាល់ជាដីរបស់រដ្ឋ។ ដូច្នេះទាំងអស់នេះ សបញ្ជាក់ថា: ជនជាប់ចោទឈ្មោ[redacted] បញ្ញាភា និងជនជាប់ចោទឈ្មោះ[redacted] ធូន ពិតជាមានគំនិតទុច្ចរិត និងដឹងយ៉ាងច្បាស់ថា: ដីទំហំ២៩៨ ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ដែលធ្វើការអភិវឌ្ឍន៍នោះ គឺមិនមែនកម្មសិទ្ធិជាក់លាក់របស់ជនជាប់ចោទឈ្មោ[redacted] ធី ហើយដីនោះអាចប៉ះពាល់ដល់ដីរបស់រដ្ឋ ឬគម្របព្រៃឈើទៀតផង។ ប៉ុន្តែជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា និងជនជាប់ចោទឈ្មោះ[redacted] ធូន បែរជាចូលរួមយ៉ាងសកម្មភាពជម្រុញសកម្មភាពក្នុងការឈូសឆាយដីព្រៃដើម្បីបំពេញតាមគម្រោងវិនិយោគក្នុងទទួលបានកម្រៃជើងសារពីជនជាប់ចោឈ្មោះ[redacted] ឈិន។ ហេតុនេះជនជាប់ចោទឈ្មោះ[redacted] បញ្ញាភា និងជនជាប់ចោទឈ្មោះ[redacted] ធូន ពិតជាមានចេតនាចូល ស



Scanned with CamScanner

រួមធ្វើការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរបហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ប្រាកដមែន។

៥-ជនជាប់ចោទឈ្មោះ[redacted] ម៉េងធី បានឆ្លើយនាពេលសវនាការបញ្ជាក់ថា: ខ្លួនធ្លាប់ទៅទីតាំងដីនោះចំនួន២ដង ដោយសារលោកអភិបាលស្រុកអូររាំងឈ្មោះ[redacted] មុន្នី បានឲ្យខ្លួនចូលទៅមើលទីតាំងដីឈូសឆាយជាប់កន្លែងកើតហេតុ។ ខ្លួនពិតជាបានប្រាប់ទៅឈ្មោះ[redacted] ធី ថាលោកអភិបាលស្រុកមិនអនុញ្ញាតឲ្យឈូសឆាយដីនោះទេ ប៉ុន្តែឈ្មោះ[redacted]ធី បានឆ្លើយថា "អញដឹងហើយចាំអញទៅជួបចៅហ្វាយស្រុក" ។ នៅពេលនោះខ្លួនឃើញមានវត្តមានឈ្មោះ[redacted] ម៉ាប់, ឈ្មោះ[redacted] សុខា ,ឈ្មោះ[redacted]ចិន្តា, ឈ្មោះ[redacted] សុភក្តិ, ឈ្មោះ[redacted]ជុង, ឈ្មោះ[redacted]សំណាង និងឈ្មោះ[redacted] សារឿន។ តាមចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ[redacted] ម៉េងធី គឺគ្មានភស្តុតាងណាមួយដែលអាចដោះបន្ទុកឲ្យខ្លួនបានឡើយ ដោយហេតុថា: តាមចម្លើយជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន បានបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] ម៉េងធី និងមនុស្សស្រីម្នាក់បានមកទំនាក់ទំនងសុំឲ្យខ្លួនជួយទៅវាស់ដីដោយគេចង់ដឹងទំហំដី ចង់ដឹងថាមានជាន់ជាមួយគេឬអត់ ដោយអ្នកស្នើសុំមានបង្ហាញពាក្យស្នើសុំកាន់កាប់មានហត្ថលេខាពីភូមិឃុំ និងឯកសារខ្លះទៀតចុះហត្ថលេខាដល់ស្រុក ហើយខ្លួនក៏បានទៅទីតាំងដីនោះជាមួយឈ្មោះ[redacted] ម៉េងធី ហើយគាត់ជាអ្នកចង្អុលបង្ហាញព្រំដីទាំងបីកន្លែងឲ្យខ្លួនវាស់វែងតាមការចង្អុលបង្ហាញពីម្ចាស់ដី។ ម្យ៉ាងវិញទៀតតាមចម្លើយជនជាប់ចោទឈ្មោះ[redacted] ម៉េងធី បានបញ្ជាក់ថា: ខ្លួនធ្លាប់ទៅទីតាំងដីនោះចំនួនពីរដង ដោយសារលោកអភិបាលស្រុកអូររាំងឈ្មោះ[redacted] មុន្នី បានឲ្យខ្លួនចូលទៅមើលទីតាំងដីឈូសឆាយដើម្បីទៅប្រាប់ជនជាប់ចោទឈ្មោះ[redacted] ធី ថា: លោកអភិបាលស្រុកមិនអនុញ្ញាតឲ្យឈូសឆាយដីនោះទេ។ ទាំងអស់នេះបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] ម៉េងធី ពិតជាបានដឹងថា: ដីទំហំ ២៩៨ ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី គឺជាដីស្ថិតនៅក្នុងដីរបៀងអភិរក្សជីវចម្រុះដែលត្រូវបានហាមឃាត់ហើយជនជាប់ចោទឈ្មោះ[redacted] ម៉េងធី ពិតជាមានទំនាក់ទំនងជិតស្និត និងរួមសហការណ៍ការងារជាមួយជនជាប់ចោទឈ្មោះ[redacted] ធី ក្នុងការសម្រេចគោលដៅឈូសឆាយព្រៃឈើដើម្បីបង្កើតវីស៊ិត និង[illegible]ឧទ្យានព្រៃរាង ឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ឈិន ទៀតផង។ ដូច្នេះជនជាប់ចោទឈ្មោះ[redacted] ម៉េងធី ពិតជាបានប្រព្រឹត្តអំពើល្មើសដូចការចោទប្រកាន់ដោយបានចូលរួមជាមួយជនជាប់ចោតឈ្មោះ[redacted] ធី ដើម្បីធ្វើសកម្មភាព[illegible]២៩៨ហិចតា ដែលជាដីរបស់រដ្ឋយកមកធ្វើជាកម្មសិទ្ធរបស់ពួកខ្លួនដោយជនជាប់ចោទឈ្មោះ[redacted] ម៉េងធី បាន[illegible]ជនជាប់ចោទឈ្មោះ[redacted] ធី ក្នុងការធ្វើសកម្មភាពរត់ការដោយទៅណាត់ជួបជាមួយអាជ្ញាធរមូលដ្ឋាន។ ទង្វើទាំងអស់នេះបង្ហាញថា: ជនជាប់ចោទឈ្មោះ[redacted] ម៉េងធី ពិតជាបានចូលរួមយ៉ាងសកម្មភាព ជម្រុញសកម្មភាពឲ្យមានការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិឯកជន ប្រព្រឹត្តនៅចំណុចភ្នំរបហាំង ភូមិ ពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ប្រាកដមែន។

៦-ជនជាប់ចោទឈ្មោះ[redacted] ជុង បានឆ្លើយនាពេលសវនាការបញ្ជាក់ថា: ខ្លួន គឺជាអ្នកចាំដីឲ្យឈ្មោះ[redacted] ធី តាំងពីឆ្នាំ២០០៧។ ខ្លួនមិនបានស្គាល់ឈ្មោះ[redacted] ឈិន នោះទេ ហើយខ្លួនក៏មិនបានដឹងថា ឈ្មោះ[redacted]ឈិន និងឈ្មោះ[redacted] ធី បានចុះកិច្ចសន្យាក្នុងការអភិវឌ្ឍន៍លើដីនោះទេ។ ខ្លួនពិតជាបានទៅមើលដីនោះមែនតាមបញ្ជារបស់ស្នងការរងហើយពេលចុះទៅដល់ខ្លួនបានឃើញឈ្មោះ[redacted] សុធារ៉ាន់ និងឈ្មោះ[redacted] ធី នៅជាមួយគ្នា ហើយក៏បានឮអ្នកទាំងពីរនិយាយគ្នាអំពីការអភិវឌ្ឍគម្រោងលើដីនោះ។ តាមចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ[redacted] ជុង គឺគ្មានភស្តុតាងណាមួយដែលអាចដោះបន្ទុកឲ្យខ្លួនបានឡើយ ដោយហេតុថា: ជនជាប់ចោទឈ្មោះ[redacted] ជុង បានឆ្លើយនៅសមត្ថកិច្ចបានបញ្ជាក់ថា: ខ្លួនជាអ្នកប្រមូលដីឲ្យជនជាប់[redacted] ចាន់ ធី។ នៅឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ[redacted] ធី បានឲ្យជនជាប់ចោទឈ្មោះ[redacted]វន យកគ្រឿងចក្រទៅឈូសឆាយនៅតំបន់នោះបានប្រហែលចំនួន ១០ហិចតា ដោយរាល់ការចំណាយលើការឈូសឆាយ គឺជនជាប់ចោទឈ្មោះ[redacted] ឈិន ជាអ្នកចេញ។ ម្យ៉ាងទៀតតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]សុភក្តិ បានបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] ជុង

ជាអ្នកកាន់ឯកសារដីដើម្បីឱ្យមេភូមិចុះហត្ថលេខាតែមេភូមិមិនបានចុះហត្ថលេខាឱ្យនោះទេ។ ដូច្នេះជនជាប់ចោទឈ្មោះ[redacted] ជុង គឺពិតជាមនុស្សរបស់ជនជាប់ចោទឈ្មោះ[redacted] ធី ក្នុងការធ្វើសកម្មភាពយ៉ាងសកម្មដើម្បីប្រមូលដីគម្របព្រៃឈើធ្វើជាកម្មសិទ្ធិ។ ម្យ៉ាងទៀតតាមចម្លើយជនជាប់ចោទឈ្មោះ[redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ[redacted] សុខា បានបញ្ជាក់ថា: នៅពេលពួកគេបានទៅដល់ដីកន្លែងអភិវឌ្ឍន៍ឈូសឆាយនោះ គឺបានឃើញវត្តមានជនជាប់ចោទឈ្មោះ[redacted] ជុង និងឈ្មោះ[redacted] សំណាង នៅទីនោះស្រាប់ដែលចម្លើយនេះមានភាពស៊ីសង្វាក់ជាមួយចម្លើយជនជាប់ចោទឈ្មោះ[redacted] ម៉េងធី បានឆ្លើយបញ្ជាក់ថា: ខ្លួនពិតជាបានប្រាប់ទៅឈ្មោះ[redacted] ធី ថាលោកអភិបាលស្រុកមិនអនុញ្ញាតឱ្យឈូសឆាយដីនោះទេ ប៉ុន្តែឈ្មោះ[redacted] ធី បានឆ្លើយថា "អញដឹងហើយចាំអញទៅជួបចៅហ្វាយស្រុក" ។ នៅពេលនោះខ្លួនឃើញមានវត្តមានឈ្មោះ[redacted] ម៉ាប់, ឈ្មោះ[redacted] សុខា, ឈ្មោះ[redacted] ចិន្តា,ឈ្មោះ[redacted] សុភក្តិ, ឈ្មោះ[redacted] ជុង, ឈ្មោះ[redacted]សំណាង និងឈ្មោះ[redacted] សារឿន។ ម្យ៉ាងទៀតតាមចម្លើយជនជាប់ចោទឈ្មោះ[redacted] ជុង នៅដំណាក់កាលនគរបាលយុត្តិធម៌បញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] ធី បានប្រើឱ្យឈ្មោះ[redacted] វន យកគ្រឿងចក្រមកឈូសឆាយនៅតំបន់នេះដោយឱ្យខ្លួនជាអ្នកមើលការខុសត្រូវលើការឈូសឆាយ។ ដូច្នេះជនជាប់ចោទឈ្មោះ[redacted] ជុង ពិតជាបានចូលរួមយ៉ាងសកម្មជម្រុញសកម្មភាពឱ្យមានការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិឯកជន ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ប្រាកដមែន។

៧-ជនជាប់ចោទឈ្មោះ[redacted]វណ្ណារ័ត្ន បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តក្រចេះ បញ្ជាក់ថា: ខ្លួនមានតួនាទីជាអនុប្រធានការិយាល័យសុរិយោដី និងភូមិសាស្ត្រ នៃមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី តាំងពីអំឡុងឆ្នាំ២០០៩ រហូតដល់បច្ចុប្បន្ន។ ក្នុងរឿងនេះដំបូងឡើយឈ្មោះ[redacted] ម៉េងធី និងមនុស្សស្រីម្នាក់បានមកទំនាក់ទំនងសុំឱ្យខ្លួនជួយទៅវាស់ដីដោយគេចង់ដឹងទំហំដី ចង់ដឹងថាមានជាន់ជាមួយគេឬអត់ ដោយអ្នកស្នើសុំមានបង្ហាញពាក្យស្នើសុំកាន់កាប់មានហត្ថលេខាពីភូមិឃុំ និងឯកសារខ្លះទៀតចុះហត្ថលេខាដល់ស្រុក ហើយខ្លួនក៏បានទៅទីតាំងដីនោះជាមួយឈ្មោះ[redacted] ម៉េងធី ហើយគាត់ជាអ្នកចង្អុលបង្ហាញព្រំដីទាំង ០៣កន្លែង ឱ្យខ្លួនវាស់វែងតាមការចង្អុលបង្ហាញពីម្ចាស់ដីហើយខ្លួនដំឡើងផែនទី គឺត្រូវជាមួយនឹងភូមិឃុំនៅក្នុងប្លង់គឺភូមិពូឆប ឃុំដាក់ដាំ តែត្រង់ចំណុចកន្លែងណា គឺអត់ដឹងទេដោយនៅក្នុងប្លង់ចាស់របស់ម្ចាស់ដីអត់មាននិយាមការ។ នៅពេលដែលចុចជីភីអេសដែលមាននិយាមការច្បាស់លាស់ គឺពុំដឹងថាតំបន់នេះស្ថិតនៅតំបន់អភិរក្សបរិស្ថាន ឬគំរបព្រៃឈើរបស់ក្រសួងកសិកម្មនោះទេដោយខាងខ្លួនពុំមានទិន្នន័យទាំងអស់នេះទេ។ ខ្លួនចុះហត្ថលេខាលើគំនូសបង្ហាញទីតាំង និងសណ្ឋានដី គឺអះអាងបញ្ជាក់ទីតាំងដី និងទំហំដីនៅទីតាំងនោះ គឺផែកមើលផែនទីដែលផ្តល់ដោយក្រសួង គឺមានទិន្នន័យផ្លូវលំហើយផ្លូវលំគឺទៅដល់កន្លែងដែលខ្លួនវាស់វែង(ជីភីអេស)ហើយការធ្វើគំនូសប្លង់នេះ គឺការពារកុំឱ្យជាន់ដីគ្នា។ ម្ចាស់ដីស្នើសុំឱ្យខ្លួនវាស់វែងដីចំនួន ០៣ប្លង់ ហើយការវាស់វែងបានកាត់ចំណីផ្លូវនៅក្នុងប្លង់នោះដែរ។ នៅពេលដែលខ្លួនបានវាស់វែងរួចគូសចេញប្លង់ និងចុះហត្ថលេខាហើយ ខ្លួនបានប្រគល់ឱ្យម្ចាស់ដីយកទៅប្រើប្រាស់។ ចំពោះរូបមន្តគំនូសបង្ហាញទីតាំងក្បាលដី និងរូបសណ្ឋានកន្លែងជ្រុងក្បាលដី គឺខាងមន្ទីររបស់ខ្ញុំជាអ្នកបន្ថែមកំណត់សម្គាល់នៅរឹមទំព័រខាងក្រោយថាគំនូសប្លង់នេះបញ្ជាក់អំពីទីតាំង និងទំហំដីតែប៉ុណ្ណោះមិនមែនបញ្ជាក់ថានៅក្រៅផែនទីគំរបព្រៃដែនការពារ ឬសម្បទានដីសេដ្ឋកិច្ចផ្សេងៗឡើយ និងរាល់ផលប៉ះពាល់លើទីតាំងដីជាការទទួលខុសត្រូវរបស់ម្ចាស់ដី។ រីឯ ជនជាប់ចោទឈ្មោះលឹម សុខេង បានឆ្លើយបញ្ជាក់នាពេលសវនាការថា: ខ្លួន គឺជាប្រធានការិយាល័យភូមិបាលស្រុកអូររាំង។ ចំពោះដីដែលមានបញ្ហានោះ គឺមន្ត្រីឈ្មោះ[redacted] វណ្ណារ័ត្ន ជាអ្នកចុះទៅវាស់វែងចុចGPS ដែលគាត់ជាមន្ត្រីជំនាញ ហើយការចុះទៅចុចGPS នោះ ខ្លួនមិនបានដឹងនោះទេ។ ចំណែកឯការ វាស់វែងទាំងអស់ គឺឈ្មោះ[redacted] វណ្ណារ័ត្ន បានចុះហត្ថលេខា និងបានបញ្ជូនឯកសារទាំងនោះឱ្យខ្លួនពិនិត្យ និងចុះហត្ថលេខាដោយមានឯកសារណបដែលមានចុះហត្ថលេខាភូមិឃុំបញ្ជាក់អំពីទំហំព្រំដីចំនួន ០៦ហិចតា ដែលស្ថិតនៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។ ខ្លួនមិនបានចុះទៅមើលទីតាំងមុនពេលចុះ

ហត្ថលេខានោះទេ ហើយខ្លួនក៏បានមិនដឹងច្បាស់ពីទំហំដីដែលជារបស់រដ្ឋនោះដែរ។ ប្រសិនបើដីទំហំ ០៦ ហិចតា នោះពាក់ព័ន្ធជាមួយដីរដ្ឋ ខ្លួនក៏មិនចុះហត្ថលេខាឱ្យនោះដែរ ហើយការចុះហត្ថលេខាបញ្ជាក់ពីទំហំនោះ គឺខ្លួនសំអាងការចុះហត្ថលេខា និងបោះត្រាលើការស្នើសុំរបស់ឈ្មោះ[redacted] សុវណ្ណារ័ត្ន និងតាមលិខិតពាក់ព័ន្ធ និងការកាន់កាប់មួយចំនួនរបស់អាជ្ញាធរភូមិឃុំ ក្នុងឆ្នាំ២០០៦ និងឆ្នាំ២០០៧។ តាមចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ[redacted] សុខេង គឺគ្មានភស្តុតាងណាមួយដែលអាចដោះបន្ទុកឱ្យខ្លួនបានឡើយ ដោយហេតុថា: តាមចម្លើយសាក្សីឈ្មោះ[redacted] ប៊ុនធឿន បានបញ្ជាក់ថា: ដីនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី មានការឈូសឆាយផ្លូវហើយជាស្រេចបានចំនួនប្រហែលជាង ១០គីឡូម៉ែត្រ ដោយមានការប៉ះពាល់ព្រៃឈើ និងមានឃើញដើមឈើធំតូចរលំជាច្រើន ហើយគេបានសម្អាតរួចហើយ។ ដីដែលជនជាប់ចោទទាំងអស់ធ្វើការឈូសឆាយនោះ គឺប៉ះពាល់ដល់ដីរបៀងអភិរក្សជីវចម្រុះដែលភ្ជាប់ពីតំបន់ការពារមួយ ទៅតំបន់ការពារមួយទៀត ហើយដីទាំងនោះមានទំហំច្បាស់លាស់ និងមានចែងក្នុងអនុក្រឹត្យលេខ ០៧អនក្របក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវចម្រុះប្រពន្ធ័តំបន់ការពារធម្មជាតិ ហើយអនុក្រឹត្យនេះខាងមន្ទីរបរិស្ថានបានដាក់ទៅរដ្ឋបាលខេត្តមណ្ឌលគីរី ធ្វើការផ្សព្វផ្សាយជាបន្តបន្ទាប់ទៀតផង។ ចំពោះដីសរុបចំនួន ២៩៨ ហិចតា គឺមិនមានប្រជាជនរស់នៅនោះទេពីព្រោះវាស្ថិតនៅក្នុងដីរបៀងអភិរក្សជីវចម្រុះទៀតផង។ ម្យ៉ាងទៀតជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ[redacted] សុខេង ជាមន្ត្រីជំនាញសុរិយោដី ដែលតម្រូវឱ្យដឹងថា: ដីដែលត្រូវការវាស់វែងនោះជាដីប៉ះពាល់ដល់ប៉ះពាល់ដល់ដីរបៀងអភិរក្សជីវចម្រុះ ឬប៉ះពាល់ដល់បរិស្ថាន ឬដីរបស់រដ្ឋ តែបែរជាជនជាប់ចោទទាំងពីរនាក់ធ្វើឱ្យមានការវាស់វែងតាមការសុំរបស់ជនជាប់ចោទឈ្មោះ[redacted] ធី ដោយយកលេ្ហសថាការចុះហត្ថលេខានោះតាមលិខិតរណបដោយមានការចុះហត្ថលេខារបស់អាជ្ញាធរ ភូមិ ឃុំ ស្រុក និងចុះហត្ថលេខាលើទម្រង់ច្បាស់លាស់ដែលអាចបណ្តាលឱ្យមានការយល់ច្រឡំពីមជ្ឈដ្ឋានទូទៅថា: ដីដែលជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ[redacted] សុខេង ជាមន្ត្រីជំនាញសុរិយោដីបានវាស់វែង និងចុះហត្ថលេខានោះ គឺជាដីមិនមានប៉ះពាល់ដល់ផលប្រយោជន៏សាធារណៈ ឬដីរបស់រដ្ឋនោះទេ។ ម្យ៉ាងទៀតតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] ធី, ជនជាប់ចោទឈ្មោះ[redacted] ឈិន, ជនជាប់ចោទឈ្មោះសាង ធូរា និងជនជាប់ចោទឈ្មោះម៉ា ម៉េងធី បានឆ្លើយបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ[illegible] សុខេង មិនបានចូលរួមក្នុងសកម្មភាពឈូសឆាយដី ឬគម្រោងអភិវឌ្ឍន៍ដីគម្របព្រៃឈើ និងមិនបានចំណាយលុយកាក់ ឬប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីសម្រួលគម្រោងអភិវឌ្ឍន៍ដីគម្របព្រៃឈើនោះទេ ហើយតាមចម្លើយរបស់សាក្សីឈ្មោះ[redacted] សុធារិទ្ធ, ឈ្មោះ[redacted] រ៉ាវី និងសាក្សីឈ្មោះ[redacted] ហ៊ុនអេង បានបញ្ជាក់ថា: នៅពេលកម្លាំងមានសមត្ថកិច្ចចុះបង្រ្កាបបទល្មើស គឺមិនឃើញមានវត្តមានជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ[redacted] សុខេង នៅទីកន្លែងកើតហេតុនោះទេ។ ផ្ទុយទៅវិញជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ[redacted] សុខេង ពិតជាបានដឹងថាមានការឈូសឆាយដីព្រៃដើម្បី[redacted] យកដីធ្វើជាកម្មសិទ្ធិឯកជនចំនួន២៩៨ ហិចតា នៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted] ធី និងគូកនបានបំពាននៅក្នុងដីរបៀងអភិរក្សជីវចម្រុះដែលមានចែងក្នុងអនុក្រឹត្យលេខ ០៧អនក្របក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវចម្រុះប្រពន្ធ័តំបន់ការពារធម្មជាតិ តែបែរជាជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ[redacted] សុខេង នៅតែមិនបានរាយការណ៍ និងប្តឹងបរិហារដល់អាជ្ញាធរមានសមត្ថកិច្ចនោះទេ។ ដូច្នេះ គ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ[redacted] សុខេង ពីបទ: ការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិឯកជន ប្រព្រឹត្ត នៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ គប្បីតុលាការពិចារណាកែប្រែបទចោទ។

៨-ជនជាប់ចោទឈ្មោះ[redacted] សុភក្តិ បានឆ្លើយនៅដំណាក់កាលរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តក្រចេះ បញ្ជាក់

ថា: ខ្លួនជានាយរងខណ្ឌរដ្ឋបាលព្រៃឈើខេត្តមណ្ឌលគីរី តាំងពីឆ្នាំ២០១៧ រហូតដល់បច្ចុប្បន្ន។ ខ្លួនធ្លាប់ទៅទីតាំងដីនោះនៅចំណុចភូមិរហាំងបានចំនួន ០៣ដង ជាមួយឈ្មោះ[redacted] សុខា ឈ្មោះ[redacted] ស្ន និងឈ្មោះ[redacted] ម៉ាប់ ដើម្បីទៅលេង និងរកត្រីហូបចុកលេងដោយឈ្មោះ[redacted] ម៉ាប់ ជាអ្នកហៅដោយខ្លួនដឹងថាទីតាំងដីនោះ គឺជាដីរបស់ឈ្មោះ[redacted] ធី។ នៅពេលខ្លួនទៅលើកទីមួយ គឺគេបានឈូសឆាយផ្លូវស្អាត និងបានបំពាក់អំពូលភ្លើងសឡា និងមានកន្លែងអង្គុយលេង មានផ្ទះមួយខ្នងរួចហើយ។ ពេលខ្លួនទៅទីនោះទាំងបីលើក គឺខ្លួនបានឃើញឈ្មោះ[redacted] ជុង និងឈ្មោះ[redacted] សំណាង ស្នាក់នៅផ្ទះលើដីនោះ។ ខ្លួនពុំបានជួយឈ្មោះ[redacted] ធី ក្នុងការធ្វើសកម្មភាពក្នុងការឈូសឆាយផ្លូវកាប់ឆ្ការព្រៃដើម្បីធ្វើការអភិវឌ្ឍន៍លើដីនោះទេ។ ក្នុងខែឧសភា ឆ្នាំ២០២០ ខ្លួនពិតជាបានទៅផ្ទះមេភូមិពូឧប ជាមួយឈ្មោះ[redacted] ម៉ាប់ និងឈ្មោះ[redacted] ស្ន ចំនួនពីរដង ដោយយកឯកសារកាន់កាប់ដីដើម្បីឲ្យគាត់ចុះហត្ថលេខាដោយឈ្មោះ[redacted] ស្ន ជាអ្នកកាន់ឯកសារជួបជាមួយមេភូមិ។ រីឯជនជាប់ចោទឈ្មោះ[redacted] សុខា បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តក្រចេះ បញ្ជាក់ថា: ខ្លួនជាមន្ត្រីរដ្ឋបាលព្រៃឈើ ឋានៈនាយផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យ តាំងពីឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន។ ខ្លួនស្គាល់ និងរាប់អានគ្នាជាមួយឈ្មោះ[redacted] សុភក្តិ ដោយបានទៅលេងនៅទីតាំងដីចំណុចភ្នំរហាំងនោះដើម្បីទៅលេង និងមានកម្មវិធីហូបចុក។ ម្យ៉ាងទៀត ខ្លួនពិតជាបានទៅលេងទីតាំងដីនោះចំនួនពីរដងលើកទី១ ឈ្មោះ[redacted] សុភក្តិ ហៅទៅអាំងត្រីហូបលេងនៅពេលទៅដល់ គឺបានឃើញគេឈូសផ្លូវពីផ្លូវជាតិមករួចហើយដល់ចំណុចដីភ្នំរហាំងនេះតែម្តង។ ខ្លួនបានដឹងថាដីចំណុចនោះ គឺជាឈ្មោះ[redacted] ធី ទិញកាលពី១០ឆ្នាំមុន ដោយខ្លួនបានដឹងពីឈ្មោះ[redacted] សុភក្តិ ជាអ្នកនិយាយប្រាប់ ពេលខ្លួនទៅបានឃើញគេធ្វើផ្ទះ និងសង់រោងនៅលើដីនោះ និងបានឃើញមានការឈូសផ្លូវពីផ្លូវជាតិ និងមានឈូសព្រៃនៅក្បែរនោះបានខ្លះ និងបានឃើញមានកម្មករពីរទៅបីកន្លែងដោយមួយកន្លែងមានមនុស្សពីរទៅបីនាក់ ដោយខ្លួនបានឃើញកម្មករនៅទីនោះរួមមាន: ឈ្មោះ[redacted] ជុង និងឈ្មោះ[redacted] សំណាង កំពុងតែមើលការខុសត្រូវសង់រោងនៅទីនោះ។ នៅលើកទី២ ក៏ខ្លួនទៅជាមួយឈ្មោះ[redacted] សុភក្តិ, ឈ្មោះ[redacted] ម៉ាប់ និងឈ្មោះ[redacted] ស្ន ដែរ ដើម្បីទៅមើលថាដីនោះអាចកាត់ឈ្វៀលចេញពីដីក្រុមហ៊ុនបាន ឬអត់គ្រាន់តែដើរមើលហើយបានអាំងត្រីហូបនៅទីនោះ ហើយខ្លួនត្រឡប់មកវិញ។ ខ្លួនក៏បានឃើញឈ្មោះ[redacted] សំណាង និងឈ្មោះ[redacted]ុង នៅលើដីនោះដែរ។ តាមចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ[redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ[redacted] សុខា គឺគ្មានភស្តុតាងណាមួយដែលអាចដោះបន្ទុកឲ្យខ្លួនបានឡើយ ដោយហេតុថា តាមចម្លើយជនជាប់ចោទឈ្មោះ[redacted] ម៉េងធី បានបញ្ជាក់ថា: ខ្លួនធ្លាប់ទៅទីតាំងដីចំនួនពីរដងដោយសារលោកអភិបាលស្រុកអូររាំងឈ្មោះ[redacted] មុន្នី បានឲ្យខ្លួនចូលទៅមើលទីតាំងដីឈូសឆាយជាប់កន្លែងកើតហេតុ។ ខ្លួនពិតជាបានប្រាប់ទៅឈ្មោះ[redacted] ធី ថា លោកអភិបាលស្រុកមិនអនុញ្ញាតឲ្យឈូសឆាយដីនោះទេ ប៉ុន្តែឈ្មោះ[redacted] ធី បានឆ្លើយថា "អញដឹងហើយចាំអញទៅជួបចៅហ្វាយស្រុក" នាខណៈពេលនោះខ្លួនឃើញមានវត្តមានឈ្មោះ[redacted] ម៉ាប់, ឈ្មោះ[redacted] សុខា, ឈ្មោះ[redacted] ចិន្តា, ឈ្មោះ[redacted] សុភក្តិ, ឈ្មោះ[redacted] ជុង, ឈ្មោះ[redacted] សំណាង និងឈ្មោះ[redacted] សាវឿន ក៏នៅទីនោះដែរ។ ដូច្នេះតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ[redacted] សុខា អាចឲ្យតុលាការជឿជាក់បានដោយហេតុថា: កិច្ចព្រមព្រៀងស្តីពីការវិនិយោគអចលនទ្រព្យរវាងឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ឈិន ឃើញថា: គ្មានវត្តមានជនជាប់ចោទឈ្មោះ[redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ[redacted] សុខា ជាសមាជិកក្រុមហ៊ុន ឬជាសាក្សីដឹងឮនោះទេហើយតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] ធី, ជនជាប់ចោទឈ្មោះ[redacted] ឈិន, ជនជាប់ចោទឈ្មោះ[redacted] ធួន និងជនជាប់ចោទឈ្មោះ[redacted] ម៉េងធី មិនបានឆ្លើយថា: ជនជាប់ចោទឈ្មោះ[redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ[redacted] សុខា បានចូលរួមក្នុងសកម្មភាពឈូសឆាយដី ឬគម្រោងអភិវឌ្ឍន៍ដីគម្របព្រៃឈើឡើយ។ មិនតែប៉ុណ្ណោះ ជនជាប់ចោទឈ្មោះ[redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ[redacted] សុខា ក៏មិនបានចំណាយប្រាក់កាក់ ឬប្រើប្រាស់តួនាទីឋានៈរបស់ខ្លួនដើម្បីសម្រួលដល់គម្រោងអភិវឌ្ឍន៍ដីគម្របព្រៃឈើនោះទេ។ ជាងនេះទៅទៀតសាក្សីឈ្មោះ[redacted] សុធារិទ្ធិ, ឈ្មោះ[redacted] រ៉ាវី និងសាក្សីឈ្មោះ[redacted] ហ៊ុនអេង បានឆ្លើយបញ្ជាក់ថា:នៅពេល



Scanned with CamScanner

កម្លាំងសមត្ថកិច្ចចុះបង្ក្រាបបទល្មើស គឺមិនឃើញវត្តមានជនជាប់ចោទឈ្មោះ [redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ [redacted] សុខា នៅទីកន្លែងកើតហេតុនោះទេ។ ដូច្នេះ គ្មានមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ [redacted] សុខា ពីបទ: កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ នៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ ប៉ុន្តែ ជនជាប់ចោទឈ្មោះ [redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ [redacted] សុខា បានឆ្លើយបញ្ជាក់ថា: ខ្លួនធ្លាប់បានទៅលេងនៅទីតាំងដីកើតហេតុបានជាច្រើនដង ហើយបានឃើញគេឈូសឆាយផ្លូវស្អាត និងបានបំពាក់អំពូលសូឡា និងមានកន្លែងអង្គុយលេង មានផ្ទះរួចហើយ និងបានដឹងថា: ដីរបស់ជនជាប់ចោទឈ្មោះ [redacted] ធី ជាដីស្ថិតនៅក្នុងច្រករបៀងរបស់ក្រសួងបរិស្ថាន ហើយខ្លួនដឹងដោយសារខ្លួនបានឆែកមើលផែនទី។ ដូច្នេះជនជាប់ចោទឈ្មោះ [redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ [redacted] សុខា ជាមន្ត្រីជំនាញដោយបានដឹង និងមើលឃើញ ដោយផ្ទាល់ភ្នែកថា: ដីរបស់ជនជាប់ចោទឈ្មោះ [redacted] ធី ជាដីស្ថិតនៅក្នុងច្រករបៀងរបស់ក្រសួងបរិស្ថានដោយជនជាប់ចោទឈ្មោះ [redacted] ធី និងជនជាប់ចោទឈ្មោះ [redacted] ឈិន ព្រមទាំងបក្សពួករួមគ្នាឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ និងធ្វើការសាងសង់ផ្សេងៗលើដីនោះក៏ដោយក៏ខ្លួននៅតែមិនព្រមប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចអំពីបទល្មើសឈូសឆាយដីព្រៃដែលខ្លួនបានដឹងនោះទេ។ តប្បីតុលាការពិចារណាកែប្រែបទចោទ។

៩-ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ាន់ បានឆ្លើយដោះសារនាពេលសវនាការថា: ឈ្មោះ [redacted] ធី បានប្រាប់មកខ្លួនថា: គេមានដីទំហំ ២៩៨ ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី និងសុំឱ្យខ្លួនរកអ្នកទិញ ឬរកដៃគូមកវិនិយោគ។ បន្ទាប់មកខ្លួនបានប្រាប់ពីគម្រោងអភិវឌ្ឍន៍ដីនេះទៅឈ្មោះ [redacted] បញ្ញាភា ហើយគេបាននែនាំខ្លួនឱ្យស្គាល់ឈ្មោះ [redacted] ឈិន ដែលជាអ្នកចង់វិនិយោគ និងឈានដល់ការចុះកិច្ចសន្យារវាងម្ចាស់ដី គឺឈ្មោះ [redacted] ធី និងអ្នកវិនិយោគឈ្មោះ [redacted] ឈិន ទើបឈានដល់ការបង្កើតលក្ខន្តិកៈក្រុមហ៊ុនដែលមានឈ្មោះ [redacted] ធី ជាប្រធានក្រុមហ៊ុន និងឈ្មោះ [redacted] ឈិន ជាអគ្គនាយកចំណែកខ្លួន, ឈ្មោះ [redacted] បញ្ញាភា និងឈ្មោះ [redacted] ធូន គឺជាសមាជិកនៃក្រុមហ៊ុន។ មូលហេតុដែលខ្លួនមានឈ្មោះជាសាក្សី និងជាសមាជិកក្នុងលក្ខន្តិកៈក្រុមហ៊ុន ដោយសាររក្សាកម្រៃជើងសាររបស់ខ្លួនដែលឈ្មោះ [redacted] ធី បានសន្យាថាឱ្យមកខ្លួន។ តាមចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ាន់ មានភាពស៊ីសង្វាក់ជាមួយបណ្តាចម្លើយជនជាប់ចោទ និងភស្តុតាងនានាអាចឱ្យតុលាការជឿបានដោយហេតុថា: ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ាន់ គ្រាន់តែជាអ្នកនែនាំឱ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញាភា ឱ្យស្គាល់ជនជាប់ចោទឈ្មោះ [redacted] ឈិន ដើម្បីមកធ្វើវិនិយោគលើដីរបស់ជនជាប់ចោទឈ្មោះ [redacted] ធី ដើម្បីខ្លួនបានកម្រៃជើងសារពីជនជាប់ចោទឈ្មោះ [redacted] ធី។ ម្យ៉ាងទៀត ការធ្វើជាសាក្សីក្នុងកិច្ចសន្យាព្រមព្រៀងវិនិយោគអចលនទ្រព្យ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ឈិន គឺដើម្បីធានាលើការសន្យាកម្រៃជើងសារតែប៉ុណ្ណោះ។ ចំណែកឯដីទំហំ ២៩៨ ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ដែលធ្វើការអភិវឌ្ឍន៍នោះ គឺជនជាប់ [redacted] ចោទឈ្មោះ [redacted] ធី ជាអ្នកធានាថាជាដីកម្មសិទ្ធិរបស់ខ្លួន ហើយក៏គ្មានហេតុផលណាមួយដាប់បង្ខំឱ្យជនជាប់ចោទឈ្មោះពៅ សុធារ៉ាន់ សិក្សាស្រាវជ្រាវពីប្រភពដីឱ្យបានច្បាស់លាស់មុននឹងនែនាំរកអ្នកអភិវឌ្ឍន៍លើដីមុនពេលដែលខ្លួននែនាំរកអ្នកវិនិយោគដោយខ្លួនគ្រាន់តែជាអ្នកយកកម្រៃជើងសារពីជនជាប់ចោទឈ្មោះ [redacted] ធី ម្នាក់ប៉ុណ្ណោះ។ ម្យ៉ាងទៀតតាមចម្លើយសាក្សីឈ្មោះ [redacted] សារី, ឈ្មោះ [redacted] ធារ៉ា, ឈ្មោះ [redacted] សុភាព និងសាក្សីឈ្មោះ [redacted] គឹមសុង បានឆ្លើយនៅសមត្ថកិច្ចបានបញ្ជាក់ថា:ពួកខ្លួនជាកម្មករធ្វើផ្ទះនៅចំណុចជើងភ្នំរបាំង ដែលជាទីកន្លែងកើតហេតុដោយពួកខ្លួនមកតាមរយៈឈ្មោះ [redacted] សំណាង។ តាមចម្លើយរបស់បណ្តាសាក្សីបញ្ជាក់បានថា: សកម្មភាពនៃការសាងសង់ផ្ទះក្នុងគម្រោងអភិវឌ្ឍន៍លើដីគម្របព្រៃឈើ គឺមិនមានការចូលរួម និងបង្គាប់បញ្ជាពីជនជាប់ចោទឈ្មោះ [redacted] សុធារ៉ាន់ នោះទេ។ ផ្អែកតាមមាត្រា៦២ និងមាត្រា៥៦ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ បានចែងថា: "ដើម្បីអាចចោទប្រកាន់លើបទល្មើសដែលមានចែងក្នុងមាត្រានេះបាន លុះត្រាតែជន...



Scanned with CamScanner

ជាប់ចោទបានចូលរួមដោយផ្ទាល់ក្នុងឋានៈជាចារី សហចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិតក្នុងការធ្វើសកម្មភាពកាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ"។ម្យ៉ាងទៀត តាមចម្លើយបណ្តាជនជាប់ចោទ និងបណ្តាសាក្សីបានឆ្លើយបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] សុផារ៉ាន់ មិនបានចូលរួមធ្វើការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ នោះទេ។ ដូច្នេះជនជាប់ចោទឈ្មោះ [redacted] សុផារ៉ាន់ គ្មានមានចេតនា និងគ្មានគំនិតទុច្ចរិតក្នុងការនែនាំជនជាប់ចោទដទៃឱ្យមកវិនិយោគលើដីទំហំ ២៩៨ ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដែលដីនោះមានការប៉ះពាល់ដល់ដីរបស់រដ្ឋ ឬគម្របព្រៃឈើ នោះទេ។ គប្បី សម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] សុផារ៉ាន់ រួចផុតពីបទចោទ ។

១០-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ធី ហៅចិត្រ, ជនជាប់ចោទឈ្មោះ [redacted] សុផារ៉ាន់, ជនជាប់ចោទឈ្មោះ [redacted] ឈិន, ជនជាប់ចោទឈ្មោះ [redacted] បញ្ញាភា, ជនជាប់ចោទឈ្មោះ [redacted] ធូន, ជនជាប់ចោទឈ្មោះ [redacted] ម៉េងធី, ជនជាប់ចោទឈ្មោះ [redacted] ដុង, ជនជាប់ចោទឈ្មោះ [redacted] សុភក្តី, ជនជាប់ចោទឈ្មោះ [redacted] សុខា, ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ័ត្ន, ជនជាប់ចោទឈ្មោះ [redacted] សុខេង និងចម្លើយបណ្តាសាក្សីមានភាពស៊ីសង្វាក់ជាមួយភស្តុតាងនានាបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] សាន ពិតជាមិនមានវត្តមាននៅទីកន្លែងកើតហេតុ និងមិនបានចូលរួមការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិឯកជន ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិ ពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ នោះទេ។

១១-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ម៉េងធី, ជនជាប់ចោទឈ្មោះ [redacted] ដុង, ជនជាប់ចោទឈ្មោះ [redacted] សុភក្តី និងជនជាប់ចោទឈ្មោះ [redacted] សុខា និងចម្លើយបណ្តាសាក្សីមានភាពស៊ីសង្វាក់ជាមួយភស្តុតាងនានាបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ហៅម៉ាប់ប៊ូស្រា ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅណាងទាហ៊ាន និងជនជាប់ចោទឈ្មោះ [redacted] វន ហៅសុវណ្ណឌី ពិតជាដឹងថា: ដីដែលធ្វើការអភិវឌ្ឍន៍ នៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី គឺជាដីរបៀងអភិរក្សជីវចម្រុះដែលត្រូវបានហាមឃាត់ តែបែរជាជនជាប់ចោទទាំងបីចូលរួមយ៉ាងសកម្មក្នុងជួយឱ្យមានការឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិឯកជនឱ្យជនជាប់ចោទឈ្មោះ [redacted] ធី នៅចំណុចភ្នំរហាំង ភូមិ ពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ទៅវិញ។ ម្យ៉ាងទៀតជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ហៅម៉ាប់ប៊ូស្រា ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅណាងទាហ៊ាន និងជនជាប់ចោទឈ្មោះ [redacted] វន ហៅសុវណ្ណឌី អវត្តមាននាពេលសវនាការ។ ដូច្នេះ ដើម្បីធានារក្សាជនជាប់ចោទទាំងបីនាក់ទុកជូនតុលាការចាត់ការតាមនីតិវិធី ដើម្បីបញ្ចប់បទល្មើសកុំឱ្យកើតជាថ្មី និងធានារក្សាសណ្តាប់ ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស និងជៀសវាងជនជាប់ចោទមិនចូលមកតុលាការនៅពេលក្រោយ។ គប្បី តុលាការចេញដីកាបង្គាប់ឱ្យចាប់-ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ហៅម៉ាប់ប៊ូស្រា ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅណាងទាហ៊ាន និងជនជាប់ចោទឈ្មោ [redacted] វន ហៅសុវណ្ណឌី ។ តាមមាត្រា៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

១២-វត្ថុចាប់យកមាននៅក្នុងកំណត់ហេតុប្រគល់-ទទួលវត្ថុតាងលេខ៤២/២០ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូង ខេត្តមណ្ឌលគិរី,កំណត់ហេតុប្រគល់-ទទួលវត្ថុតាងលេខ៤៣/២០ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី, លិខិតហេតុប្រគល់-ទទួលជនសង្ស័យ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌខេត្តមណ្ឌលគិរី, លិខិតប្រគល់ទទួលជនសង្ស័យ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី និងលិខិតប្រគល់-ទទួលជនសង្ស័យ និងសម្ភារៈ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌខេត្តមណ្ឌលគិរី។ គប្បីតុលាការពិចារណា។

១៣-តាមចម្លើយបណ្តាជនជាប់ចោទមានភាពស៊ីសង្វាក់ជាមួយបណ្តាចម្លើយសាក្សី,របាយការណ៍លេខ:០២៦/២០រ.ប.ក



Scanned with CamScanner

ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការខេត្តមណ្ឌលគីរី និងលិខិតលេខ៥៧១/២១របក.បស្ត.មគរ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ របស់មន្ទីរបរិស្ថានខេត្តមណ្ឌលគីរី ព្រមទាំងភស្តុតាងជាឯកសារនានាបញ្ជាក់ថា: ជនជាប់ចោទទាំង១៣នាក់ ពិតជាមានឆន្ទៈរួមគ្នាដោយបង្កើតក្រុមចាត់តាំងក្នុងការទទួលខុសត្រូវតាមមុខងាររៀងៗខ្លួនដើម្បីបង្កើតជំនឿទុកចិត្តដូចជាមានការវាស់វែងដើម្បីឈានដល់ការធ្វើការចុះបញ្ជីដី(វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) ដោយធ្វើការឈូសឆាយដីព្រៃទំហំ ២៨៩ហិចតា នៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ទោះបីជាមានការប៉ះពាល់ដល់របៀងអភិរក្សជីវចម្រុះដែលភ្ជាប់ពីតំបន់ការពារមួយទៅតំបន់ការពារមួយទៀតដោយដីទាំងនោះមានទំហំច្បាស់លាស់ និងមានចែងក្នុងអនុក្រឹត្យលេខ ០៧ អនក្របក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីតំបន់របៀងអភិរក្សជីវចម្រុះក៏ដោយ។

១៤-ចម្លើយជនជាប់ចោទ ចម្លើយបណ្តាសាក្សី មានភាពស៊ីសង្វាក់ជាមួយភស្តុតាងនានាដែលដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ធី ហៅចិត្រ, ជនជាប់ចោទឈ្មោះ [redacted] ឈិន, ជនជាប់ចោទឈ្មោះ [redacted] បញ្ញាភា, ជនជាប់ចោទឈ្មោះ [redacted] ធូន, ជនជាប់ចោទឈ្មោ [redacted] ម៉េងធី, ជនជាប់ចោទឈ្មោះ [redacted] ផុង, ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ហៅម៉ាប់ប៊ូស្រា, ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅណាង ទាប៊ាន និងជនជាប់ចោទឈ្មោះ [redacted] វន ហៅសុវណ្ណឌី ពីបទ: កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

១៥-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ធី ហៅចិត្រ, ជនជាប់ចោទឈ្មោះ [redacted] ឈិន, ជនជាប់ចោទឈ្មោះ [redacted] បញ្ញាភា, ជនជាប់ចោទឈ្មោះ [redacted] ធូន, ជនជាប់ចោទឈ្មោះ [redacted] ម៉េងធី, ជនជាប់ចោទឈ្មោះ [redacted] ផុង, ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ហៅម៉ាប់ប៊ូស្រា, ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅណាង ទាប៊ាន និងជនជាប់ចោទឈ្មោះ [redacted] វន ហៅសុវណ្ណឌី ពីបទ: កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។

១៦-ចម្លើយជនជាប់ចោទ ចម្លើយបណ្តាសាក្សីមានភាពស៊ីសង្វាក់ជាមួយភស្តុតាងនានាដែលដាក់បន្ទុកលើជនជាប់ចោទ ជនជាប់ចោទឈ្មោះ [redacted] សុភក្តិ, ជនជាប់ចោទឈ្មោះ [redacted] សុខា, ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ [redacted] សុខេង ពីបទ: មិនប្តឹងបរិហារបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយអ្នករាជការសាធារណៈជាអាទិ៍ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៥២៨ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

១៧-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ [redacted] សុភក្តិ, ជនជាប់ចោទឈ្មោះជ័យ សុខា, ជនជាប់ចោទឈ្មោះ វណ្ណារ័ត្ន និងជនជាប់ចោទឈ្មោះ [redacted] សុខេង ពីបទ: មិនប្តឹងបរិហារបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយអ្នករាជការសាធារណៈជាអាទិ៍ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។

១៨-ចម្លើយជនជាប់ចោទ ចម្លើយបណ្តាសាក្សី មានភាពស៊ីសង្វាក់ជាមួយភស្តុតាងនានាដែលដាក់មិនអាចដាក់បន្ទុកលើជនជាប់ចោទឈ្មោះពៅ សុធារ៉ាន់ និងជនជាប់ចោទឈ្មោះ [redacted] សាន ពីបទ: កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

១៩-គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទជនជាប់ចោទឈ្មោះ [redacted] សុធារ៉ាន់ និងជនជាប់ចោទឈ្មោះ [redacted] សាន



Scanned with CamScanner

ពីបទ: កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ គប្បី តុលាការសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទ។ តាមមាត្រា៣៥០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២០-ជនជាប់ចោទមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួន និងចំពោះមុខច្បាប់។

២១-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ គប្បីតុលាការពិចារណា។

២២-មេធាវីការពារឱ្យជនជាប់ចោទទាំង១៥នាក់បានធ្វើសេចក្តីសន្និដ្ឋានការពារសុំ ឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទ។ គប្បីតុលាការពិចារណា។

២៣-សកម្មភាពល្មើសរបស់ជនជាប់ចោទប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម។

២៤-ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ័ត្ន, ជនជាប់ចោទឈ្មោះ [redacted] សុខេង, ជនជាប់ចោទឈ្មោះ [redacted] សុភក្តិ និងជនជាប់ចោទឈ្មោះ [redacted] សុខា ជាមន្ត្រីជំនាញដោយបំពេញការងារតាមជំនាញរបស់ខ្លួន តែដោយជនជាប់ចោទទាំងបួននាក់មានការធ្វេសប្រហែស និងខ្វះការពិចារណាក្នុងការទទួលខុសត្រូវលើការងារបណ្តាលឱ្យមានការប្រព្រឹត្តបទល្មើស។ គប្បី តុលាការពិចារណាផ្តល់ស្ថានសម្រាលលើការផ្តន្ទាទោស។ តាមមាត្រា៩៦ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២៥-ជនជាប់ចោទខ្វះការពិចារណាបណ្តាលឱ្យជម្រុញប្រព្រឹត្តបទល្មើស និងទើបប្រព្រឹត្តជាលើកដំបូង។

## ហេតុដូច្នេះសម្រេច

**១**-កែប្រែបទចោទលើ:

**ក**-ឈ្មោះ [redacted] **សុភក្តិ** ភេទប្រុស អាយុ ៤៥ឆ្នាំ។

**ខ**-ឈ្មោះ [redacted] **សុខា** ភេទប្រុស អាយុ ៤៨ឆ្នាំ។

**គ**-ឈ្មោះ [redacted] **វណ្ណារ័ត្ន** ភេទប្រុស អាយុ ៣៣ឆ្នាំ។

**ឃ**-ឈ្មោះ [redacted] **សុខេង** ភេទប្រុស អាយុ ៤៤ឆ្នាំ។

ពីបទ:**កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ** បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ មកជាបទ: **មិនប្តឹងបរិហារបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយអ្នករាជការសាធារណៈជាអាទិ៍** បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៥២៨ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

30%

**២**- ឱ្យរួចខ្លួនលើឈ្មោះ [redacted] **សុធារ៉ាន់** ភេទប្រុស អាយុ ៤៣ឆ្នាំ និងឈ្មោះ [redacted] **សាន** ភេទប្រុស ពីបទ: **កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**៣**-ផ្តន្ទាទោសលើ:

**ក**-ឈ្មោះ [redacted] **សុភក្តិ** ភេទប្រុស អាយុ ៤៥ឆ្នាំ ដាក់ពន្ធនាគារកំណត់១(មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

**ខ**-ឈ្មោះ [redacted] **សុខា** ភេទប្រុសអាយុ៤៨ឆ្នាំ ដាក់ពន្ធនាគារកំណត់១(មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

**គ**-ឈ្មោះ [redacted] **វណ្ណារ័ត្ន** ភេទប្រុសអាយុ ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១(មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

ឃ-ឈ្មោ [redacted] សុខេង ភេទប្រុស អាយុ ៤៤ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១(មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

ពីបទ: **មិនប្តឹងបរិហារបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយអ្នករាជការសាធារណៈជាអាទិ៍** ប្រព្រឹត្តនៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៩៧ មាត្រា១០៧ និងមាត្រា៥២៨ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៤-ផ្តន្ទាទោសលើ:

**ក**-ឈ្មោ [redacted] **ធី** ហៅ**ចិត្រ** ភេទប្រុស អាយុ ៥៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៨(ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០០(មួយរយ)លានរៀល។

**ខ**-ឈ្មោះ [redacted] **ឈិន** ភេទប្រុស អាយុ ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០(ហុកសិប)លានរៀល។

**គ**-ឈ្មោះ [redacted] **បញ្ញាតា** ភេទប្រុស អាយុ ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០(ហុកសិប)លានរៀល។

**ឃ**-ឈ្មោះ [redacted] **ធូន** ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០(ហុកសិប)លានរៀល។

**ង**-ឈ្មោះ [redacted] **ម៉េងធី** ភេទប្រុស អាយុ ៤៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០(ហុកសិប)លានរៀល។

**ច**-ឈ្មោះ [redacted] **ដុង** ភេទប្រុស អាយុ ៥១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០(ហុកសិប)លានរៀល។

**ឆ**-ឈ្មោះ [redacted] **ម៉ាច់** ហៅ**ម៉ាច់ម៉ីស្រា** ភេទប្រុស អាយុ ៤២ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០(ហុកសិប)លានរៀល។

**ជ**-ឈ្មោះ [redacted] **សំណាង** ហៅ**ណាងទាហ៊ាន** ភេទប្រុស អាយុ ៤៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០(ហុកសិប)លានរៀល។

**ឈ**-ឈ្មោ [redacted] **វន** ហៅ**សុវណ្ណឌី** ភេទប្រុស អាយុ ៦០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០(ហុកសិប)លានរៀល។

ពីបទ:**កាប់គាស់រុករានដីព្រៃ ឆ្ការព្រៃ និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ** ប្រព្រឹ[redacted] នៅចំណុចភ្នំរហាំង ភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

៥-បង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនលើ:

**ក**-ឈ្មោះ [redacted] **ម៉ាច់** ហៅ**ម៉ាច់ម៉ីស្រា** ភេទប្រុស អាយុ ៤២ឆ្នាំ។

**ខ**-ឈ្មោះ [redacted] **សំណាង** ហៅ**ណាងទាហ៊ាន** ភេទប្រុស អាយុ ៤៧ឆ្នាំ។

**គ**-ឈ្មោ [redacted] **វន** ហៅ**សុវណ្ណឌី** ភេទប្រុស អាយុ ៦០ឆ្នាំ។

យកមកឃុំខ្លួននៅពន្ធនាគារខេត្តក្រចេះ ដើម្បីឲ្យមកទទួលទណ្ឌកម្មតាមអំណាចសាលក្រមនេះ។ តាមមាត្រា៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។/.



Scanned with CamScanner

៦-រឹបអូសវត្ថុចាប់យក នូវៈ ឧបករណ៍វាស់ប្រវែងម៉ាក Bosch ពណ៌ខៀវលាយខ្មៅ ចំនួន ០១គ្រឿង។

៧-ប្រគល់វត្ថុចាប់យក នូវៈ-ទូរស័ព្ទម៉ាក VIVO ពណ៌ខៀវ ចំនួន ០១គ្រឿង។ -ទូរស័ព្ទម៉ាក OPPO A3 ពណ៌ក្រហ.. ចំនួន ០១គ្រឿង និងទូរស័ព្ទម៉ាក OPPO 11PRO ពណ៌សលាយស្វាយ ចំនួន ០១ គ្រឿង។ -ទូរស័ព្ទដៃចំនួន០២ គ្រឿង ម៉ាក OPPO F9 ប្រើប្រាស់លេខ០៩៧ ៥៧៩៨ ៧០៨ និងទូរស័ព្ទដៃម៉ាកNOKIA ចុចពិល ប្រើប្រាស់លេខ០៩៦ ៩៥០ ១២៦៤។ -ទូរស័ព្ទដៃម៉ាក Iphone Xs Max ពណ៌ទឹកមាស, ទូរស័ព្ទម៉ាក OPPO ពណ៌ទឹកសមុទ្រ, កុំព្យូទ័រ Laptop ម៉ាក Dell, កាតធនាគារអេស៊ីលីដាចំនួន ០៤កាត, កាតធនាគារABA ចំនួន ០១កាត, ប័ណ្ណបើកបរលេខៈB00១៩០៤២៥ និងលិខិតឆ្លងដែនលេខ N0១៣៨៥៣៨៦។ និងទូរស័ព្ទចំនួន ០២គ្រឿង ម៉ាកSAMSUNG ពណ៌ទឹកសមុទ្រ, ម៉ាក OPPO ពណ៌ទឹកប៊ិច និងចិញ្ចៀនលោហធាតុដាំត្បូងពណ៌សចំនួន ០១វង់ និងរថយន្តម៉ាក Montaro ពណ៌ស ពាក់ស្លាកលេខភ្នំពេញ 2I-5875 ចំនួន ០១គ្រឿង ឲ្យទៅម្ចាស់ដើមវិញ។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធី ហៅចិត្រ, ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ាន់, ជនជាប់ចោទឈ្មោ[redacted] ឈិន, ជនជាប់ចោទឈ្មោះ [redacted] បញ្ញាសា, ជនជាប់ចោទឈ្មោះ [redacted] ធូន, ជនជាប់ចោទឈ្មោ[redacted] ម៉េងធី, ជនជាប់ចោទឈ្មោះ [redacted] ដុង និងជនជាប់ចោទឈ្មោះ [redacted] សុខេង និងកំបាំងមុខជនជាប់ចោទឈ្មោ[redacted] វណ្ណារ័ត្ន, ជនជាប់ចោទឈ្មោះ [redacted] សុភក្តី, ជនជាប់ចោទឈ្មោ[redacted] សុខា, ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ហៅម៉ាប់ម៉ិស្រា, ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅណាងធាហ៊ាន, ជនជាប់ចោទឈ្មោ[redacted] វន ហៅសុវណ្ណឌី និងជនជាប់ចោទឈ្មោះ [redacted] សាន។ ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

**បានឃើញ**

ក្រចេះ, ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៥កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ក្រចេះ, ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១

ក្រឡាបញ្ជីសវនាការ

[redacted]



Scanned with CamScanner